ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ
លេខ: ២៥៦០
ចុះថ្ងៃទី១០/០៨/២០១២

សាលក្រមព្រហ្មទណ្ឌ
លេខ: ១០៧ (ឃ)
ចុះថ្ងៃទី ២៧/ធ្នូ/២០១២

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅសាលាដំបូងរាជធានីភ្នំពេញនាថ្ងៃទី ២៦ , ២៧ ខែ ធ្នូ ឆ្នាំ ២០១២ វេលាម៉ោង ០៨ : ០០ ព្រឹក និង ១៤ : ០០ រសៀល ដែលមានសមាសភាពជំនុំជម្រះដូចតទៅ:

**ចៅក្រមជំនុំជម្រះ**

លោក [redacted] អនុប្រធានសាលាដំបូងរាជធានីភ្នំពេញ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើជនជាប់ចោទឈ្មោះ ១.ឈ្មោះ [redacted] ភេទ ស្រី អាយុ ២៨ ឆ្នាំ ជាតិខ្មែរ មុខរបរ នៅផ្ទះ ទីកន្លែងកំណើតស្រុករតនៈមណ្ឌល ខេត្តបាត់ដំបង ទីលំនៅ បច្ចុប្បន្នផ្ទះលេខ ២១៨ ផ្លូវ ៨៦ ភូមិ ២២ ក្រុម ២៧៧ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted]) ប្តីឈ្មោះ [redacted] មានកូន ០១ នាក់ ទោសពីមុន គ្មាន ឃាត់ខ្លួននៅថ្ងៃទី០៨ ខែ កញ្ញា ឆ្នាំ ២០១២ ឃុំខ្លួនថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០១២ ទោសពីមុនគ្មាន។

២.ឈ្មោះ [redacted] ភេទ ប្រុស អាយុ ៥៦ ឆ្នាំ ជាតិខ្មែរ មុខរបរនៅផ្ទះ ទីកន្លែងកំណើតភូមិ ឬស្សីក្រោក ឃុំឬស្សីក្រោក ស្រុកមង្គលបូរី ខេត្ត បន្ទាយមានជ័យ ទីលំនៅបច្ចុប្បន្នផ្ទះលេខ ២១៨ ផ្លូវ ៨៦ ភូមិ ២២ ក្រុម ២៧៧ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] ប្រពន្ធឈ្មោះ [redacted] បុប្ផា មានកូន ០១ នាក់ ទោសពីមុន គ្មាន (ក្រៅឃុំ) ។

៣.ឈ្មោះ [redacted] ហៅ [redacted] ភេទ ប្រុស អាយុ ៣០ ឆ្នាំ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នផ្ទះលេខ ២១៨ ភូមិ ២២ ក្រុម ២៧៧ សង្កាត់ ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] ទោសពីមុន គ្មាន (ក្រៅឃុំ) ។

៤. ឈ្មោះ [redacted] ភេទ ប្រុស អាយុ ២៧ ឆ្នាំ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នផ្ទះលេខ ២១៨ ផ្លូវ ៨៦ ក្រុម ២៧៧ សង្កាត់ស្រះចក ខណ្ឌ ដូនពេញ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ទោសពីមុន គ្មាន ។



Scanned by CamScanner

ពីបទៈ ហឹង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុច ផ្ទះសំណាក់បុប្ផា ទីតាំងផ្ទះលេខ ៥ ផ្លូវ ៨៦ ភូមិ ២២ សង្កាត់ ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១២ ។

បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ

-មានលោកមេធាវី [redacted] លោកមេធាវី [redacted] និងលោកមេធាវី [redacted] ជាមេធាវីការពារក្តីឱ្យជនជាប់ចោទឈ្មោះ [redacted]

រឿងហេតុមានដូចតទៅ: កាលពីថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១២ វេលាម៉ោង ១៩ និង ១០ នាទី នៅមុខផ្ទះសំណាក់បុប្ផា មានករណី ហឹង្សាដោយចេតនា មានស្ថានទម្ងន់ទោស មួយកើតឡើង បានបង្កឡើងដោយឈ្មោះ [redacted] បាននាំបងប្អូនឈ្មោះ [redacted] ដើរសំដៅទៅជនរងគ្រោះឈ្មោះ [redacted] ឈ្មោះ [redacted] ដែលអង្គុយចាំមួយនៅកន្លែងកើតហេតុខាងលើពេលនោះឈ្មោះ [redacted] កន្លង់ ដែលមានទូលីវីស និង ដៃបានចាប់ក្រៀកឈ្មោះ [redacted] ហើយយក ទូលីវីស ចាក់លើក្បាល បណ្តាលអោយរងរបួសជាច្រើនកន្លែង និងចាក់ត្រង់ខ្នងចំពោះ ដៃផុត ចំនួន ០១ កន្លែងទៀត រីឯឈ្មោះ [redacted] បានយកពូថៅកាប់ទៅលើឈ្មោះ [redacted] ចំក្បាល របួស ០២ កន្លែង បណ្តាលអោយហូរឈាមភ្លាមនោះឪពុករបស់ឈ្មោះ [redacted] និង អ្នកជិតខាង បានចូលឃាត់ចាប់បានជនល្មើសម្នាក់ឈ្មោះ [redacted] ជាបងស្រីបង្កើតរបស់ឈ្មោះ [redacted] និង ប្តី បានមកជួយរំដោះ ប្អូនអោយរួចរត់គេចខ្លួនបាត់អស់ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទ ប្រុស អាយុ ២៨ ឆ្នាំ មុខរបររត់ម៉ូតូឌុប ទីលំនៅបច្ចុប្បន្នផ្ទះជួល ផ្លូវលេខ ៨៦ ភូមិ ១២ សង្កាត់ ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទ ប្រុស អាយុ ២៥ ឆ្នាំ មុខរបរ រត់ម៉ូតូឌុប មានទីលំនៅផ្ទះជួល ផ្លូវ ៨៦ ភូមិ ២២ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ

-មានលោកមេធាវី [redacted] និងលោកមេធាវី [redacted] មេធាវីការពារក្តី ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ១៧៥៤ អយង ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១២ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាបញ្ជូនសំណុំរឿងទៅជំនុំជំរះលេខ ២៩២៧ ដជរ ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០១២ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសម្រេចយកជនជាប់ចោទមកជំនុំជំរះលេខ ១៥១៥៤ តព្រ ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១២ របស់ចៅក្រមជំនុំជំរះរបស់សាលាដំបូងរាជាធានីភ្នំពេញ ។

បានឃើញ:

-ចម្លើយរបស់ជនត្រូវចោទឈ្មោះ [redacted] នៅចៅក្រមស៊ើបសួរបំភ្លឺថា ៖ នៅមុនពេលកើតហេតុប្រហែល ១០ ថ្ងៃ ខ្លួនបានបាត់កញ្ចក់ឡានចំនួន ៣ ដងមកហើយ ខ្លួនបានដាក់ពាក្យបណ្តឹងទៅសមត្ថកិច្ចប៉ុស្តិ៍ តែពុំឃើញសមត្ថកិច្ចដោះស្រាយអោយសោះ នៅថ្ងៃ



Scanned by CamScanner

69

ទី ០៧ ខែ សីហា ឆ្នាំ ២០១២ ខ្លួននិងប្តី បានដើរទៅលេងផ្ទះរបស់ [redacted] ពេល កំពុងជជែកគ្នាលេង ស្រាប់តែឃើញមានការប្រតាយប្រតប់គ្នានៅ មុខផ្ទះសំណាក់ បុប្ផា ដោយមានមនុស្ស ២ ក្រុម វៃគ្នាទៅវិញទៅមក ។ ខ្លួន និង ប្តី ក៏ស្រែកអោយអ្នកជិត ខាង ជួយឃាត់តែខ្លួនពុំបានស្គាល់មុខជនទាំង ២ ក្រុមនោះទេ ដោយសារពេលព្រលប់មេឃ ងងឹតមើលមិនស្គាល់ថាជាអ្នកណាឡើយ ក្រោយពីអ្នកជិតខាងជួយឃាត់ក៏បែកគ្នាអស់ទៅ ហើយខ្លួននិងប្តីក៏នៅឈរជជែកគ្នាលេងជាមួយអ្នកជិតខាង នៅទីកន្លែងនោះរួមជាមួយ ឈ្មោះ [redacted] ដែរស្រាប់តែឪពុករបស់ជនរងគ្រោះនិងជនរងគ្រោះបានមកចង្អុល មុខខ្លួនថាជាបក្សពួកនាំប្អូនមកវៃពួកគេ ។ ខ្លួនពុំបានដឹងថាបងប្អូនរបស់ខ្លួនជាអ្នកវៃពួកគេ នោះទេ ខ្លួនគ្រាន់តែចូលទៅជួយឃាត់តែប៉ុណ្ណោះ ។ ចំពោះការចោទប្រកាន់ថាខ្លួនបាន ចូលទៅប្រឡេះដៃពីអ្នកម៉ូតូឌុបដើម្បីអោយប្អូនរត់នោះវាពុំមែនជាការពិតទេ ព្រោះពេលគេ វៃគ្នាខ្លួនពុំហ៊ានចូលទៅជិតផង គ្រាន់តែឈរស្រែកពីចំងាយប៉ុណ្ណោះ ។ ចំពោះប្អូនប្រុស របស់ខ្លួនទាំងពីរនាក់នេះដោយសារខ្លួននិយាយពុំស្តាប់ ខ្លួនបានដេញចេញពីផ្ទះមិនអោយ ស្នាក់នៅជាមួយជាងមួយឆ្នាំមកហើយ ។ ខ្លួនពុំដែលនិយាយពាក្យថា អាញមកវៃអាចោរ លួចកញ្ចក់ឡាននោះទេ ។

-ចម្លើយរបស់ជនត្រូវចោទឈ្មោះ [redacted] នៅចៅក្រមស៊ើបសួរបំភ្លឺថាៈ នៅថ្ងៃ កើតហេតុខ្លួនបានជិះម៉ូតូតែម្នាក់ឯងក្នុងគោលបំណងទៅផ្សារទិញឥវ៉ាន់ ពេលជិះដល់មុខ ផ្ទះរបស់ឈ្មោះ [redacted] ឈប់ជជែកគ្នាលេង ស្រាប់តែឃើញប្រពន្ធរបស់ខ្លួនមកដល់ ផ្ទះ យាយ [redacted] ដែរ ។ ពេលជជែកគ្នាលេងបានមួយសន្ទុះ ស្រាប់តែមានរឿងប្រតាយប្រតប់ គ្នាកើតឡើងនៅក្នុងផ្ទះលក់គ្រឿងផឹកស៊ី ដោយឃ្លាតពីកន្លែងដែលខ្លួនអង្គុយជជែកគ្នាប្រ ហែល ១០ ម៉ែត្រ ។ នៅពេលវាយតប់គ្នានោះម៉ោងជាង ៧ យប់មើលឃើញគ្នាព្រាលៗ ខ្លួន ពុំបានដឹងថាអ្នកណាវៃជាមួយអ្នកណាទេ ។ ពេលនោះពួកខ្លួននិងអ្នកជិតខាងបាននាំ គ្នា ចូលទៅឃាត់បំបែកចេញ នៅពេលបញ្ចប់ហេតុការណ៍ ស្រាប់តែឪពុកជនរងគ្រោះមក ចង្អុលមុខប្រពន្ធរបស់ខ្លួនថាជាអ្នកនាំបងប្អូនមកវៃកូនគាត់ ។ ក្រោយពីត្រឡប់មកដល់ផ្ទះ វិញទើបខ្លួនបានដឹងថាអ្នកដែលវៃគេនោះគឺប្អូនថ្លៃ និងបងថ្លៃរបស់ខ្លួនឈ្មោ[redacted] ឈ្មោ[redacted] ។ ចំពោះរូបខ្លួនពុំបានស្គាល់ឈ្មោះទាំងពីរនេះទេ ព្រោះពេលដែលខ្លួនមករស់ នៅក្នុងផ្ទះជាមួយប្រពន្ធ ឈ្មោះទាំងពីរនេះបានចេញពីផ្ទះបាត់ទៅហើយ ដោយឮប្រពន្ធ និយាយថាពួកគេទាំងពីរនេះប្រដៅមិនស្តាប់ ហើយនាំរឿងចូលផ្ទះទៀតក៏ដេញចេញពីផ្ទះ តែម្តង ។

-ចម្លើយរបស់ដើមបណ្តឹងជាជនរងគ្រោះឈ្មោះ [redacted] នៅសមត្ថកិច្ចនគរបាល និងនៅអយ្យការ និងនៅចៅក្រមស៊ើបសួរ ឆ្លើយបំភ្លឺប្រហាក់ប្រហែលគ្នាថាៈ នៅយប់ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១២ វេលាម៉ោង ១៩ និង ១០ នាទី ពេលខ្លួនកំពុងអង្គុយចាំ ម៉ូយនៅ ចំណុចមុខផ្ទះ សំណាក់បុប្ផា ទីតាំងផ្ទះលេខ ៥ ផ្លូវលេខ ៨៦ ភូមិ ២២ សង្កាត់ ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ស្រាប់តែមានឈ្មោះ [redacted] ស្គាល់ឈ្មោះ បាននាំបងប្អូន ឈ្មោ[redacted] កចង្អុលមុខខ្លួននិង មិត្តភក្រ័ខ្លួនឈ្មោ[redacted] ដោយចោទប្រកាន់ថាបានលួច កាត់កញ្ចក់រថយន្ត



Scanned by CamScanner

ភ្លាមនោះឈ្មោះ [redacted] ដែលមានកាន់ទូលីវ៉ែសនៅនឹងដៃបានចាក់ មកលើក្បាលខ្លួន បណ្តាលអោយរងរបួសចំនួន ០៤ កន្លែង និងចំគ្រង់ខ្នងបោះដៃផុតចំនួន ០១ កន្លែងទៀត ហូរឈាម ចំណែកឈ្មោះ [redacted] បានយកពូថៅកាប់ទៅលើមិត្តភក្រ័ ខ្លួនឈ្មោះ [redacted] បណ្តាលអោយ របួសច្រើនកន្លែងបន្ទាប់មកខ្លួននិងឈ្មោះ [redacted] ត្រូវបានឪពុករបស់ខ្លួនយកម៉ូតូកង់បី ដឹកទៅសង្គ្រោះនៅមន្ទីរពេទ្យកាល់ម៉ែត ។

-ចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] នៅសមត្ថកិច្ចនគរបាលនិងនៅអយ្យការ និងចៅក្រមស៊ើបសួរ ឆ្លើយបំភ្លឺប្រហាក់ប្រហែលគ្នាថា៖ នៅថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១២ វេលាម៉ោង ១៩ និង ១០ នាទី ខ្លួនបានដើរទៅអង្គុយលេងជាមួយឈ្មោះ [redacted] នៅចំណុចមុខផ្ទះសំណាក់បុប្ផា ទីតាំងផ្ទះលេខ ៥ ផ្លូវ ៨៦ ភូមិ ២២ សង្កាត់ ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ស្រាប់តែឈ្មោះ [redacted] និងប្តីបាននាំបងប្អូនឈ្មោះ [redacted] និងឈ្មោះ [redacted] ដែលមានកាន់ ពូថៅ និង ទូលីវ៉ែស នៅនិងដៃដោយ ឈ្មោះ [redacted] បុប្ផា បានចង្អុលមកខ្លួននិងឈ្មោះ [redacted] ចោទប្រកាន់ថាពួកខ្លួនបាន លួចកញ្ចក់រថយន្តរបស់គាត់ ភ្លាមនោះឈ្មោះ [redacted] បានយកពូថៅស្ទុះ មកកាប់លើក្បាលខ្លួនបណ្តាលអោយត្រូវចំហៀងក្បាលខាងឆ្វេង ហូរឈាម បន្ទាប់មកជន ល្មើសបាននាំគ្នារត់គេចខ្លួនបាត់អស់ ។

-ចម្លើយរបស់សាក្សីឈ្មោះ [redacted] នៅសមត្ថកិច្ចនគរបាលឆ្លើយបំភ្លឺថា ៖ នៅថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១២ វេលាម៉ោងប្រហែល ១៦ និង ០០ នាទី ខ្លួនកំពុងអង្គុយចាំម៉ូយនៅចំនុចមុខផ្ទះសំណាក់សួស្តី ទីតាំង ផ្ទះលេខ ០៥ ផ្លូវ ៨៦ ភូមិ ២២ សង្កាត់ស្រះចក ខណ្ឌ ដូនពេញ រាជធានីភ្នំពេញ ស្រាប់តែមានក្មេងប្រុសម្នាក់រត់មកប្រាប់ ថាមានគេកាប់ឈ្មោះ [redacted] និងឈ្មោះ [redacted] នៅក្នុងផ្ទះសំណាក់បុប្ផា ខ្លួនបានរត់ទៅមើល ស្រាប់តែឃើញឈ្មោះ [redacted] បានក្រៀកក ឈ្មោះ [redacted] យកទុលីវ៉ែសមុខបួនដងជ័រ ពណ៌ខៀវ ចាក់លើក្បាល បណ្តាលអោយហូរឈាមរួចឈ្មោះ [redacted] បានរត់គេចខ្លួនបាត់ទៅចំណែក [redacted] បានដើរចេញតាមក្រោយខ្លួនក៏ចាប់ឈ្មោះ [redacted] ប់តែត្រូវបងស្រី និងបងប្រុសឈ្មោះ [redacted] មកប្រតាយប្រតប់ដើម្បីបណ្តោះ [redacted] អោយរត់គេចខ្លួនព្រមទាំងព្រមានខ្លួនថាកុំអោយចេះ វ៉ៃតែចោរលួចកាច់ កញ្ចក់រថយន្តរបស់គេ ។

-ចម្លើយរបស់សាក្សីឈ្មោះ [redacted] ជាឪពុកជនរងគ្រោះឈ្មោះ [redacted] នៅសមត្ថកិច្ចនគរបាល និងនៅអយ្យការ និងនៅចៅក្រមស៊ើបសួរ ឆ្លើយបំភ្លឺប្រហាក់ប្រហែលគ្នាថា៖ នៅថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១២ វេលាម៉ោងប្រហែល ១៩ និង ១០ នាទី ខ្លួនកំពុងអង្គុយចាំម៉ូយចៅចំនុចមុខ ផ្ទះសំណាក់សួស្តី ទីតាំផ្ទះលេខ ០៥ ផ្លូវ ៨៦ ភូមិ ២២ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ពេលនោះមានក្មេងរត់ឆោឡោប្រាប់ថាមានគេព្រួតវ៉ៃកូនអ៊ុំឯង ភ្លាមនោះខ្លួនក៏ទៅដល់ផ្ទះ សំណាក់បុប្ផា ខ្លួនឃើញឈ្មោះ [redacted] ចាក់មកលើកូនខ្លួនឈ្មោះ [redacted] ហើយឈ្មោះ [redacted] កាន់ពូថៅ គំរាមខ្លួនថា (បើហ៊ានចូលជួយប្រយ័ត្នគេកាប់) ពេលនោះខ្លួនក៏ដើរចូលទៅជិតរួច ប្រតាយ ប្រតប់គ្នាហើយឈ្មោះ [redacted] បានហែកអាវរបស់វារុំពូថៅរត់គេចខ្លួនតែ ឈ្មោះ [redacted]



Scanned by CamScanner

[redacted]ជួយចាប់បានស្រាប់តែឈ្មោះ[redacted]និងប្តីបានមកជួយទាញដៃ អោយឈ្មោះ[redacted]ត់គេចខ្លួនបាត់បន្ទាប់មកខ្លួនក៏សួរឈ្មោះ[redacted]ាហេតុអ្វី បានជាធ្វើអញ្ចឹងឈ្មោះ[redacted]ឆ្លើយថា (អាញចង់សំលាប់វាចោល) ។

-ចម្លើយរបស់សាក្សីឈ្មោះ [redacted]នៅសមត្ថកិច្ចនគរបាល និងអយ្យការ និងចៅក្រមស៊ើបសួរ ឆ្លើយបំភ្លឺប្រហាក់ប្រហែលគ្នាថាៈ នៅថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១២ វេលាម៉ោង ១៩ និង ១០ នាទី ខ្លួនកំពុងអង្គុយហូបបាយនៅផ្ទះពេលនោះមានឈ្មោះ[redacted] និងឈ្មោះ [redacted] បានទៅនិយាយគ្នានៅទីនោះដែរ បន្ទាប់មកក៏មានមនុស្សប្រុស ០១ នាក់ និងស្រី ០១នាក់ បានមក ដល់ហើយបាននិយាយជាមួយឈ្មោ[redacted]តខ្លួនមិនលឺបន្ទាប់មកក៏មាន មនុស្សប្រុស ០២ នាក់ ទៀតបានសួរទៅមនុស្សប្រុសស្រីដែលមកមុននោះ ( នឹងហើយអ្នក ដែលកាច់យកកញ្ចក់រថយន្ត) រួចជន ០១ នាក់ ដែលកាន់ទូលីវែសបានចាប់ក្រៀកឈ្មោ[redacted]កទូលីវែស ចាក់លើក្បាលឈ្មោ[redacted]ាច្រើនបណ្តាលអោយមានរបួសហូរឈាម រីឯ ជនម្នាក់ទៀតដែលកាន់ពូថៅកាប់ទៅលើឈ្មោះ[redacted]បណ្តាលអោយហូរឈាមភ្លាម នោះក៏មានការផ្អើលឆោឡោ បងប្អូនអ្នករត់ម៉ូតូឌុបនៅក្បែរនោះបាននាំគ្នាជួយចាប់បានជន ម្នាក់ដែលកាន់ទុលីវែស តែបានមនុស្សប្រុសម្នាក់និងស្រីម្នាក់ មកប្រតាយប្រតប់ដណ្តើម យកអ្នកដែលកាន់ទុលីវែសនោះឱ្យរត់គេចខ្លួនបាត់ រីឯជនដែលកាន់ពូថៅម្នាក់ទៀតក៏បានរត់ គេចខ្លួនបាត់ដែរ ។

-ចម្លើយសាក្សីឈ្មោះ[redacted]នៅចៅក្រមស៊ើបសួរឆ្លើយបំភ្លឺថាៈ នៅថ្ងៃមិនចាំខែមិនចាំឆ្នាំ ២០១២ វេលាម៉ោងប្រហែលជា ៧ ជាងជិត ៨ យប់ខ្លួនបាន អង្គុយលេងនៅមុខផ្ទះរបស់ខ្ញុំបានមួយសន្ទុះស្រាប់តែឃើញឈ្មោះ [redacted]ដើរពីជើងទៅត្បូងដោយពុំដឹងថាគោលបំណងរបស់គាត់ទៅណានោះទេ ។ ពេលដែលឈ្មោះ [redacted] នេះដើរមកដល់មុខផ្ទះរបស់ខ្លួនឃើញ ខ្លួនអង្គុយ នៅមុខផ្ទះ ស្រាប់តែឈប់ហើយបកឈរជជែកគ្នាជាមួយខ្លួនអំពីរឿងប្លង់ដីនិងផ្ទះ នៅពេល ជជែកគ្នាបានប្រហែលជាងជិត ១០ នាទី ស្រាប់តែមានរឿងវាយគ្នាចម្ងាយ ១០ ម៉ែត្រជាងពីផ្ទះរបស់ ខ្លួនស្នាក់នៅ ។ចំពោះខ្លួនពុំបានដើរមកមើលគេវាយគ្នានោះទេចំណែកឈ្មោះ[redacted] នោះបានដើរមកមើលកន្លែងដែលកំពុងកើតហេតុដោយឈ្មោះ [redacted]នេះមកឈរមើល គេដោយឈរស្ងៀមពុំមានបញ្ចេញសំលេងឬសកម្មភាពអ្វីទាំងអស់ ខ្លួនពុំបានដឹងថា ប្រជា ពលរដ្ឋនៅទីនោះក្រោយពីកើតហេតុចាប់បានជនល្មើសណានោះទេ ព្រោះយប់មានភាពងងឹតចំពោះជនប្រព្រឹត្តបទល្មើសទាំង ពីរនាក់នោះខ្លួនពុំដឹងថាជាសាច់ញ្ញាតិរបស់ឈ្មោ[redacted] ទេហើយខ្លួនក៏ពុំស្គាល់ជន ប្រព្រឹត្តបទល្មើសទាំងពីរនាក់នោះដែរ ។

ចំពោះរឿងថាពួកម៉ូតូឌុប ចាប់បានជនប្រព្រឹត្តបទល្មើសម្នាក់ឈ្មោះ [redacted] ហើយត្រូវឈ្មោះ[redacted] នេះទៅប្រតាយប្រតប់បន្លេះដៃអោយជនល្មើសរត់គេច ខ្លួននោះគឺនាងខ្ញុំពុំបានដឹងទេ ព្រោះពេលនោះមានមនុស្សច្រើនពេក ។

ខ្លួនសូមបញ្ជាក់ថាឈ្មោះ[redacted] ពុំបានចូលរួមវៃនោះទេ ចំពោះរឿងហេតុនេះ គឺខ្លួនដឹងតែប៉ុណ្ណឹងទេក្រៅពីនេះខ្លួនពុំបានដឹងរឿងអ្វីទៀតទេ ។

នាពេលសវនាការ



Scanned by CamScanner

-ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថាៈ ខ្លួនមានអាយុ ២៩ ឆ្នាំ ទោសពីមុនគ្មានត្រូវចាប់ខ្លួនកាលពីថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១២ចាប់ឃាត់ខ្លួននៅមុខរ៉ារថភ្លើង ។ ខ្លួនបានដឹងពីបទចោទប្រកាន់រួចហើយពីបទ ប្រើហឹង្សាដោយចេតនា ។ នៅថ្ងៃកើតហេតុ ខ្លួនបានដើរហាត់ប្រាណក្នុងភូមិពីខាងជើងទៅខាងត្បូង ខ្លួនបានឈរនិយាយលេងជាមួយម៉ីង [redacted] ។ ពេលឈរនោះខ្លួនឈរនៅចំងាយប្រហែល ១០ ម៉ែត្រ ទៅ ១៥ ម៉ែត្រពីកន្លែងកើតហេតុដោយលឺសំលេងមនុស្ស និងឃើញមនុស្សច្រើននៅកន្លែងកើតហេតុខ្លួនបានដើរទៅឈរមើលហើយក៏បានដើរត្រឡប់មកផ្ទះម៉ីង [redacted] ។ បន្ទាប់មកស្រាប់តែមានមនុស្សប្រុសម្នាក់បានមកចង្អុលខ្លួនថាបាននាំគ្នាទៅវាយកូនគាត់ ។ ពេលដែលខ្លួនឈរជាមួយម៉ីង [redacted] ខ្លួនឈរនៅទីនោះស្រេចហើយ កំពុងនិយាយលេងជាមួយម៉ីង [redacted] ។ ពេលខ្លួនឈរមើលនៅម៉ោងប្រហែល ៦ ទៅ ម៉ោង ៧ យប់ដោយឃើញមនុស្សច្រើនពេកខ្លួនដើរត្រឡប់មកវិញដោយពុំបានឃើញគេវ៉ាយគ្នាទេ ។ អ្នកទាំងពីរក្រុមវ៉ាយគ្នានោះខ្លួនពុំបានស្គាល់ទេ ។ ខ្លួនលឺមានគេស្រែកឱ្យជួយឃាត់ ខ្លួនបានស្រែកឱ្យគេជួយឃាត់ដែរ តែពុំបានចូលទៅធ្វើអន្តរាគមន៍នៅកន្លែងកើតហេតុនោះទេព្រោះកន្លែងនោះងងឹត ។ ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយបន្តថាៈ ខ្លួនពុំដែលមានទំនាស់ជាមួយជនរងគ្រោះទេ ខ្លួនបានបាត់កញ្ចក់ឡានមែនតែពុំបានដឹងអ្នកណាជាអ្នកលួចកញ្ចក់ឡានរបស់ខ្លួនទេ ។ ឈ្មោះ [redacted] បងប្អូនខ្លួនមែនតែពុំបានរស់នៅជាមួយខ្លួនអស់រយៈពេលពីរទៅបីឆ្នាំមកហើយ ខ្លួនពុំបានដឹងពួកគេមកបង្កហេតុនោះទេ ។ ខ្លួនពុំចូលរួមប្រតាយប្រតប់ជាមួយជនរងគ្រោះទេ ។ ខ្លួនឈរនៅជិត [redacted] គាត់អង្គុយនៅខាងក្រោយខ្ទង់ជ្រុងខាងលិចជាផ្ទះកើតហេតុ ។ ឈ្មោះ [redacted] ត្រូវជាបង របស់ខ្លួន ចំណែកឈ្មោះ [redacted] ជា ប្អូន ពុំបានដឹងរស់នៅទីណាទេ ។

-ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថាៈ ខ្លួនត្រូវជាប្តីរបស់ឈ្មោះ [redacted] យុ ៥៦ ឆ្នាំទោសពីមុនគ្មាន ខ្លួនពុំបានចាំថ្ងៃខែកើតហេតុទេចាំឆ្នាំ២០១២ នៅម៉ោងប្រហែល ៧ យប់ ខ្លួនបានជិះម៉ូតូពីជើងទៅត្បូងឃើញឈ្មោះ [redacted] អង្គុយនៅមុខផ្ទះខ្លួនបានឈប់នៅមុខផ្ទះគាត់រួចនិយាយលេងជាមួយគាត់មួយសន្ទុះឃើញប្រពន្ធខ្លួន [redacted] ដើរមកដែរ ។ ពេលនិយាយបានប្រហែល ២០ នាទីបានលឺសម្រែកស្រែកឱ្យជួយផង ។ អ្នកគេវ៉ាយគ្នាចេញពីកន្លែងលក់ស្រាខ្លួនបានដើរទៅមើលឃើញគេប្រតាយប្រតប់គ្នាមិនបានដឹងអ្នកណាជាមួយអ្នកណាទេ ហើយខ្លួនបានដើរត្រឡប់មកផ្ទះម៉ីង [redacted] វិញបន្ទាប់មកមានមនុស្សប្រុសម្នាក់បានដើរមកដោយនិយាយថា គ្រួសារខ្លួននាំបក្សពួកទៅវ៉ាយគាត់នៅពេលនោះ [redacted] បានឆ្លើយថាកុំចេះតែចោទគេផ្តេសផ្តាស ។ ប្រពន្ធខ្លួន [redacted] ដើរពីជើងមកត្បូងជួបខ្លួនដោយប្រាប់ថាទៅរកទិញអីដោយឃើញសំលៀកបំពាក់ស្លៀកឈុត ដើរមកជួបគ្នាដោយពុំបានណាត់គ្នាទេ ។ ប្រពន្ធខ្លួនឈ្មោះ [redacted] ឈរនៅក្បែរខ្លួនពីកន្លែងខ្លួនឈរនៅកន្លែងកើតហេតុចំងាយប្រហែល ១០ ម៉ែត្រដោយនៅទីនោះងងឹតមើលពុំស្គាល់គ្នាទេ ។ ប្រពន្ធខ្លួនដើរទៅកន្លែងកើតហេតុមើលមុនចំណែកខ្លួនដើរតាមពីក្រោយដោយឈរនៅខាងក្រៅទេពុំបានចូលទៅ



Scanned by CamScanner

ខាងក្នុងមើលទេ ដោយពុំបានដឹងភាគីជម្លោះជាអ្នកណាទេទាំងជនរងគ្រោះ ទាំងជនជាប់ចោទ ។ ក្រោយពីកើតរឿងហើយទើបលឺអ្នកភូមិថា បងប្អូនរបស់ [redacted] ជាអ្នកវ៉ៃ ។ ពេលខ្លួនដើរទៅដល់កន្លែងកើតហេតុឃើញប្រតាយប្រតប់គ្នាមិនស្គាល់អ្នកណាទេ ។ ជនរងគ្រោះដើរចេញមកឈរជិតខ្លួនឃើញចេញឈាម ។ជនជាប់ចោទឈ្មោះ [redacted] ខន បានឆ្លើយបន្តថាៈ ខ្លួនរស់នៅជាមួយប្រពន្ធខ្លួនចំណែកប្អូនថ្លៃខ្លួនឈ្មោះ [redacted] នពុំដែលជួបមុខទេ ។ ខ្លួន និងប្រពន្ធខ្លួនពុំបានរៀបការទេគឺបានគ្នាត្រឹមតែសែនព្រេនតែប៉ុណ្ណោះខ្លួនរស់នៅជាមួយប្រពន្ធខ្លួនទោះបីទៅខេត្តក៏ប្រពន្ធទៅជាមួយដែរ ។ នៅពេលកើតហេតុនោះខ្លួនពុំបានចូលឃាត់អ្នកឈ្លោះគ្នាទេ ។ ខ្លួនពុំដែលស្គាល់ជនរងគ្រោះទេ ។

-ជនរងគ្រោះឈ្មោះ [redacted] ហៅ [redacted] បានឆ្លើយថាៈ នៅថ្ងៃកើតហេតុទី ០៧ ខែសីហា ឆ្នាំ២០១២ ម៉ោងប្រហែល ៧ និង ១០ នាទីឈ្មោះ [redacted] និងប្រពន្ធឈ្មោះ [redacted] បាននាំបងប្អូនមកវ៉ៃខ្លួននៅកន្លែងហូបស្រាដោយមានទូលីវ៉ុស និងពូថៅបានចាក់ និងកាប់ពួកខ្លួនតែម្តង ។ ខ្លួនជាអ្នករត់ម៉ូតូនៅទីនោះដោយអង្គុយចាំម៉ូយនៅមុខផ្ទះសំណាក់ តាំងពីព្រឹករហូតដល់ល្ងាចអ្នកណាក៏ខ្លួនដឹកដែរ ។ ខ្លួនពុំធ្លាប់មានទំនាស់ជាមួយជនជាប់ចោទទេខ្លួនស្គាល់ជនជាប់ចោទឈ្មោះ [redacted] ឈ្មោះ [redacted] ព្រោះជាអ្នកផ្ទះនៅជិតខាងគ្នាដោយខ្លួនរស់នៅទីនោះជាង ០៣ ឆ្នាំមកហើយផ្ទះខ្លួន និងផ្ទះ [redacted] ជញ្ជាំងផ្ទះជាប់គ្នាខ្លួនស្គាល់ច្បាស់ ។ នៅពេលខ្លួនកំពុងអង្គុយផឹកស្រាលេងជាមួយមិត្តភ័ក្រឈ្មោះ [redacted] ឃើញឈ្មោះ [redacted] នាំបងប្អូនគាត់ឈ្មោះ [redacted] មក ពេលនោះឈ្មោះ [redacted] បានកាប់ចាក់ពួកខ្លួនតែម្តងដោយពុំបាននិយាយសួរនាំអ្វីទេដោយមិត្តភ័ក្រខ្លួនឈ្មោះ [redacted] ត្រូវឈ្មោះ [redacted] ជាអ្នកយកពូថៅកាប់រីឯខ្លួនឈ្មោះ [redacted] បានយកទូលីវ៉ុសចាក់ចំក្បាលជាច្រើនកន្លែង ។ កាំបិត និងទូលីវ៉ុសបង និងប្អូនគាត់ជាអ្នកកាន់មក ឈ្មោះ [redacted] បានមកចង្អុល បង្ហាញខ្លួនរួចបានដើរទៅឈរជាមួយ [redacted] វិញ បន្ទាប់មកប្អូន និងបងគាត់បានចូលមកវ៉ៃខ្លួនតែម្តង ។ [redacted] បានមកចាប់គ្រៀក ករបស់ខ្លួនជាប់រួចហើយបានយកទូលីវ៉ុសចាក់ខ្លួនត្រូវត្រង់សៀតផ្កា មួយទូលីវ៉ុសចំពោះដៃផុត មួយទូលីវ៉ុស និងចាក់ចំក្បាលចំនួន ០៤ ទូលីវ៉ុសទៀត ។ រីឯមិត្តភ័ក្រខ្លួនឈ្មោះ [redacted] ត្រូវឈ្មោះ [redacted] ាប់ពីរពូថៅ ។ ពេលវាយគ្នានោះមានអ្នកម៉ូតូឌុបមកជួយអន្តរាគមន៍រួចចាប់បានឈ្មោះ [redacted] តត្រូវឈ្មោះ [redacted] មកជួយរំដោះប្រតាយគ្នាទាញដៃអ្នកចាប់ឱ្យបងប្អូនគាត់រត់គេចខ្លួនបាត់តែម្តង ។ អ្នកដែលចាប់ [redacted] នោះគឺឈ្មោះ [redacted] ។ កញ្ចាក់ឡានរបស់ឈ្មោះ [redacted] បាត់ពីរបីថ្ងៃមកហើយពេលដែលគាត់ចាប់ទាញដៃឱ្យប្អូនគាត់រត់នោះគាត់ស្រែកថាប្អូនគាត់កាប់តែចោរលួចកញ្ចាក់ឡានគាត់ទេ ។ មុនពេលមានរឿងនោះខ្លួនលឺថាប្អូនគាត់ឈ្មោះ [redacted] ប់នៅចំការ ។

-ជនរងគ្រោះឈ្មោះ [redacted]ានឆ្លើយបន្តទៀតថា: ខ្លួនឈប់សម្រាក ឈប់រត់ម៉ូតូឌុបនៅម៉ោង ៦ ហើយបានទៅអង្គុយហូបស្រាដោយពេលទៅនោះឃើញ ឈ្មោះ [redacted]ង្គុយនៅចាំនៅកន្លែងហូបស្រាមុនរួចហើយ ហូបស្រាផ្ទាំបណ្ដាលពេញ ប្រហែលកន្លះលីត ។ ខ្លួនមិនសូវចាំទេព្រោះក្បាលខ្លួនត្រូវគេចាក់ ។ ខ្លួនមករស់នៅទីនោះ អស់រយៈពេល០៣ ឆ្នាំ ផ្ទះជួលនៅជាប់ផ្ទ[redacted]។ ខ្លួនស្គាល់ [redacted]ងប្ដីគាត់ [redacted]ាស់ ។[redacted]ានមាឧរាងធំ សំបុរសណ្ដែកបាយ កំពស់ ១,៦៨ ៣ ។ ឈ្មោះ [redacted]ឈរពីក្រៅមើល ។ ខ្លួនមិនដឹងថា [redacted]យាយអ្វីជាមួយបងប្អូនគាត់ទេតែគាត់បានចង្អុលខ្លួនប្រាប់បងប្អូនរបស់គាត់ហើយក៏ដើរទៅវិញទៅបន្ទាប់មកបងប្អូនគាត់ដើរចូលមកទាំងពីរនាក់មកកាប់ និងចាក់ពួកខ្លួនតែម្ដង ។ ទូលីវ៉ុសដែលចាក់ខ្លួនប្រវែងប្រហែល ៥ ហ៊ុនដងជ័រពណ៌បៃតង ។ ទូលីវ៉ីសជ្រុះនៅកន្លែងកើតហេតុពេលដែលឈ្មោះ [redacted] មកជួយចាប់តែពេលដែលរត់រួចបានរើសយកទូលៃវ៉ុសរត់យកទៅជាមួយ ។ ខ្លួនស្គាល់[redacted]ព្រោះត្រូវជាបងប្អូន[redacted]ប្រសិនបើគេចាប់បានខ្លួនស្គាល់មុខ ។ តែបើឱ្យខ្លួននិយាយរៀបរាប់ទ្រង់ទ្រាយវិញនោះខ្លួនមិនអាចរៀបរាប់បានទេ ។ ពេលដែលឈ្មោះ [redacted]ចាប់ប្រលេះឱ្យប្អូនគាត់រត់នោះឈ្មោះ [redacted]ឈរនៅក្បែរនោះដែរ ។ ខ្លួនទៅព្យាបាលនៅមន្ទីរពេទ្យកាល់ម៉ែត្រ ឪពុកខ្លួនជាអ្នកនាំទៅពេទ្យ ក្នុងរឿងនេះខ្លួនប្ដឹងទាមទារថ្លៃរបួស និងជម្ងឺចិត្តចំនួន ១០.០០០ ដុល្លា ( មួយម៉ឺនដុល្លាអាមេរិក ) ។

-ក្រឡាបញ្ជីបានអានកំណត់ហេតុសួរចម្លើយជនរងគ្រោះឈ្មោ[redacted]

-ក្រឡាបញ្ជីបានអានកំណត់ហេតុសួរចម្លើយជនរងគ្រោះឈ្មោះ [redacted]

-ជនរងគ្រោះឈ្មោះ [redacted]ានឆ្លើយថា: ថ្ងៃកើតហេតុទី ០៧ ខែ សីហា ឆ្នាំ ២០១២ ។ ខ្លួនឈប់សម្រាកពីការងារបានចូលហូបស្រានៅមុខផ្ទះសំណាក់ បុប្ផា ពេលមកដល់កន្លែងហូបស្រានោះម៉ោងប្រហែល ៤ ហើយបានអង្គុយចាំមិត្តភ័ក្រខ្លួនឈ្មោះ [redacted]។ ពេលខ្លួនកំពុងអង្គុយផឹកស្រាប់តែមានមនុស្ស០២នាក់ចូលមកកាប់ និងចាក់ពួកខ្លួនដោយខ្លួនពុំបានដឹងមូលហេតុអ្វីឡើយ ។ អ្នកដែលមកកាប់ និងចាក់ពួកខ្លួននោះខ្លួនមិនស្គាល់ទេ ចំណែកឈ្មោះ [redacted] ខ្លួនមិនស្គាល់ទេ ។ គេមកវៃខ្លួននោះគេថាខ្លួនបានទៅកាច់កញ្ចក់ឡានគេ ។ ខ្លួនត្រូវគេកាប់ត្រូវ ០២ ពូថៅ ហើយខ្លួនបានស្រែកឱ្យគេជួយដោយបានរត់ចូលទៅក្នុងផ្ទះ អ្នកដេញវៃខ្លួនបានស្រែកថាកាប់ឱ្យងាប់ ។ ពេលប្រតាយប្រតប់រត់គេចស្រែកឱ្យគេជួយនៅក្នុងផ្ទះនោះប្រហែល ១៥ នាទី ។ ក្រោយមកទើបឪពុករបស់ឈ្មោ[redacted]គាត់មកជួយទើបពួកវារត់ចេញទៅក្រៅ ។ ខ្លួនពុំដែលមានទំនាស់ជាមួយពួកនោះទេ ។ ផ្ទះខ្លួននៅផ្សារទួលសង្កែ ខ្លួនស្គាល់ [redacted]ាំមួយឆ្នាំហើយត្រូវជាបងប្អូនខាងឪពុកខ្លួន ។[redacted] បានប្រតាយប្រតប់ប្រកែកគ្នាប្រឡេះដៃប្អូនគាត់ជាមួយអ្នករត់ម៉ូតូឌុបដែលចាប់បានឱ្យប្អូនគាត់រត់ ។ ខ្លួនប្ដឹងទាមទារសំណងជម្ងឺចិត្ត និងថ្លៃថ្នាំព្យាបាលរបួសចំនួន ១០.០០០ ដុល្លា ( មួយម៉ឺនដុល្លាអាមេរិក ) ។

Scanned by CamScanner

-ជនរងគ្រោះឈ្មោះ [redacted] បានឆ្លើយបន្តទៀតថា: ខ្លួនបានសម្រាកព្យាបាលរបួសអស់ប្រាក់ចំនួន ៨០០ ដុល្លាជាង ។ ខ្លួនហូបស្រាថ្នាំអស់ជិតមួយលីតស្រវឹងរាងស្រៀងៗដែរ ខ្លួនអាចចាំមុខអ្នកដែលកាប់ខ្លួនបានឈ្មោះ [redacted]ជាអ្នកកាប់រាងខ្ពស់មាឌស្តើងសំបុរសណ្តែកបាយ ពេលកាប់នោះឈាមពេញខ្លួនហើយទៅដល់មន្ទីរពេទ្យសន្លប់ ។ អ្នករត់ម៉ូតូនៅទីនោះថាបងប្អូនឈ្មោះ [redacted]ជាអ្នកកាប់ ។ ឈ្មោះ [redacted]ជាអ្នក [redacted]ាអ្នកកាប់ ។ បើសិនមិនរត់គេចទេប្រហែលគេកាប់ងាប់ហើយ ។ ចម្លើយដែលខ្លួនឆ្លើយនៅនគរបាលខ្លួនយក ។ ខ្លួនរក្សាចម្លើយនៅពេលសវនាការ ។

-ក្រឡាបញ្ជីបានអានចម្លើយរបស់ឈ្មោ[redacted]។

-សាក្សីឈ្មោ[redacted]បានឆ្លើយថា: ខ្លួនបានស្បថរួចហើយត្រូវជាឪពុកជនរងគ្រោះឈ្មោ[redacted]នៅថ្ងៃកើតហេតុទី ០៧ ខែ សីហា ឆ្នាំ ២០១២ វេលាម៉ោង ០៧ និង ១០ នាទីមានកូនក្មេងរត់ទៅប្រាប់ថាមានគេទៅកាប់ចាក់កូនខ្លួនហើយខ្លួនបានទៅជួយពេលទៅដល់ឃើញ[redacted] កំពុងកាប់ចាក់កូនខ្លួនហើយឃើ[redacted]ឈរនៅទីនោះ ។ ឈ្មោ[redacted] បានយកទូលីវ៉ែសចាក់ទៅលើក្បាលកូនខ្លួន និងឈ្មោះ [redacted]បានកាប់ទៅលើឈ្មោះ [redacted] នៅទីនោះមានពន្លឺអំពូលពីផ្ទះសំណាក់អាចមើលឃើញស្គាល់មនុស្សដែលវាយកូនខ្លួន ។ កូនខ្លួនឱ្យឈ្មោះ [redacted]ចាប់ក្លែរជាប់ដោយយកទូលីវ៉ែសចាក់ ។ ពេលនោះខ្លួនបានចាប់ឈ្មោះ [redacted] បានតែឈ្មោះ [redacted]បានមករំដោះចាប់ប្រលេះដៃឱ្យប្អូនរត់ពេលនោះឈ្មោះ[redacted]ក៏បានមកជួយដែរ ។ ខ្លួនស្គាល់ឈ្មោះ[redacted] និងប្តីឈ្មោ[redacted]ច្បាស់ចំណែកឈ្មោ[redacted]និងឈ្មោះ[redacted] នាក់បងប្អូន ខ្លួនមិនសូវស្គាល់ច្បាស់ទេ ។ ឈ្មោះ [redacted]ចោទថាកូនខ្លួន និងឈ្មោះ [redacted]បានលួចកាច់គញ្ចក់ឡានរបស់គាត់ ។

-សាក្សីឈ្មោះ [redacted]បានឆ្លើយបន្តទៀតថា: ខ្លួននៅជិតកន្លែងកើតហេតុចំងាយប្រហែលមួយម៉ែត្រកន្លះ ។ ខ្លួនបានរត់ដេញតាមឈ្មោះ[redacted]កន្លែងដែរបានរត់ចូលកន្លែងងងឹតបាត់ ។ ប្រសិនបើចាប់ឈ្មោះ [redacted]និងឈ្មោះ [redacted]បាននោះខ្លួនស្គាល់ចាំមុខ ។ ចំពោះក្មេងប្រុសដែលរត់ទៅប្រាប់ខ្លួននោះខ្លួនមិនស្គាល់ឈ្មោះ ទេ ។ ឈ្មោះ ង៉ែត ចិត្តត្រូវគេកាប់ចំក្បាលឃើញក្តោបក្បាល គេកាប់សន្លប់ ។ ខ្លួនបានដឹកកូនទៅប្តឹងនៅប៉ុស្តិ៍នគរបាលរួចបានជូនទៅពេទ្យ ។

-ក្រឡាបញ្ជីបានអានចម្លើយសាក្សីឈ្មោះ[redacted]

-សាក្សីឈ្មោះ [redacted] បានឆ្លើយថា: ខ្លួនស្បថរួចហើយមិនជាប់សាច់ឈាមខាងណាទេ ខ្លួនជាអ្នករត់ម៉ូតូឌុប នៅចាំម៉ូយនៅមុខផ្ទះសំណាក់ សួរ ស្តី ។ ពេលដែលខ្លួនកំពុងអង្គុយ លឺសំលេងព្រាវស្រាប់តែមានក្មេងម្នាក់រត់មកប្រាប់ថាឈ្មោះ[redacted]និងឈ្មោះ [redacted]ត្រូវគេកាប់សំលាប់ហើយពេលនោះឈ្មោ[redacted]ឪពុករបស់ឈ្មោះ [redacted] បានរត់ទៅមុនខ្លួន ចំណែកខ្លួនរត់ទៅតាមក្រោយ ពេលទៅដល់ឃើញឈ្មោះ[redacted]ក្រៀកជនរងគ្រោះឈ្មោះ [redacted] ហៅ [redacted]ជាប់ហើយបានយកទូលីវ៉ែ



Scanned by CamScanner

សចាក់ ។ ខ្លួនបានចាប់ឈ្មោះ [redacted] មកបេះដៃខ្លួនចេញឱ្យប្អូនរត់ហើយថាកុំឱ្យចេះដឹងរឿងរបស់គេគេវ៉ៃតែចោរលួចកញ្ចក់ឡានទេ ។ នៅទីនោះមានភ្លើងអាចមើលឃើញ ហើយមានមនុស្សស្រែកឱ្យជួយចាប់ឃាតក ។ ខ្លួនស្គាល់ឈ្មោះ [redacted] ព្រោះធ្លាប់ជួយគាត់ដែរដោយពេលនោះផ្ទះគាត់មានរឿងចោរចូល ។ ខ្លួនបានស្រែកឱ្យថាហេតុអ្វីដោះលែងឃាតកគាត់ថាធ្វើអីគាត់ ។ ជនរងគ្រោះជាអ្នករត់ម៉ូតូឌុបជាមួយគ្នា ។

-សាក្សីឈ្មោះ [redacted] នឆ្លើយបន្តថា៖ [redacted] ធ្លាប់ជិះម៉ូតូឌុបខ្លួន ទើបខ្លួនស្គាល់ ។ ឈ្មោះ [redacted] ានកាន់ទូលីវ៉ុសដងខៀវ ។

-ក្រឡាបញ្ជីបានអានកំណត់ហេតុសួរចម្លើយសាក្សីឈ្មោះ [redacted]

-សាក្សីឈ្មោះ [redacted] បានឆ្លើយថា៖ ខ្លួនបានស្បថរួចហើយមិនជាប់សាច់ឈាមខាងណាទេ នៅថ្ងៃកើតហេតុទី ០៧ ខែ សីហា ឆ្នាំ ២០១២ វេលាម៉ោង ០៧ ខ្លួនបានឃើញបុរសពីរនាក់ចូលទៅកាប់មនុស្ស ០២ នាក់ដែលកំពុងអង្គុយហូបស្រា ដោយកាប់និងពូថៅចាក់ និងទូលីវ៉ុស ។ មនុស្សម្នាក់ដែលគេចាប់ក្រៀកកជាប់នោះត្រូវគេចាក់នឹងទូលីវ៉ុស ឃើញដូចនេះខ្លួនបានទៅហៅឪពុករបស់គាត់ ។ មុនពេលបុរសពីរនាក់នោះចូលទៅវ៉ៃ ខ្លួនឃើញឈ្មោះ [redacted] ានចូលទៅសួរ ជនរងគ្រោះទាំងនោះដែលកំពុងហូបស្រាចូលប្រហែល ប្រាំ នាទីស្រាប់តែឃើញមនុស្សពីរនាក់ចូលទៅវាយជនរងគ្រោះ ។ នៅកន្លែងកើតហេតុនោះអត់មានរបងទេ ហើយអត់មានអ្នកណាចូលជួយទេ ។ ម៉ូតូឌុបបានចាប់បានឈ្មោះ [redacted] ត្រូវឈ្មោ [redacted] នរំដោះ ដោយប្រតាយប្រតប់ជាមួយម៉ូតូឌុបឱ្យជនល្មើសរត់ ។

-សាក្សីឈ្មោះ [redacted] បានឆ្លើយបន្តទៀតថា៖ ពេលកើតហេតុនោះខ្លួនហូបបាយនៅទីនោះ ឈ្មោះ [redacted] និង ឈ្មោះ [redacted] អង្គុយនៅទីនោះ ។ ខ្លួនរត់ទៅប្រាប់ឪពុកជនរងគ្រោះតែម្នាក់ឯងទេពុំមានក្មេងប្រុសទេ ។ ខ្លួនមិនស្គាល់ឈ្មោះ អ្នកកាប់ និងអ្នកចាក់ទាំងពីរនាក់នោះទេ ។ ជនរងគ្រោះឈ្មោះ [redacted] អត់សន្លប់ទេតែហូរឈាមច្រើន ។ ពូម៉ូតូឌុបនៅទីនោះជាអ្នកចាប់ជនល្មើសបានទើបឪពុកជនរងគ្រោះមកតាមក្រោយ ។

សាក្សីឈ្មោះ [redacted] បានឆ្លើយថា៖ ខ្លួនបានស្បថរួចហើយមិនជាប់សាច់ឈាមខាងណាទេ ថ្ងៃកើតហេតុនោះខ្លួនអង្គុយនៅមុខផ្ទះ ។ ឈ្មោះ [redacted] ៈម៉ូតូកាត់មុខផ្ទះគាត់ហើយបានឈប់ជជែកជាមួយខ្លួនបន្ទាប់មកប្រពន្ធគាត់ឈ្មោះ [redacted] មកតាមក្រោយដែរសួរខ្លួនថា ហូបបាយហើយឬនៅ ។ ពេលកំពុងជជែកគ្នាខ្លួនលឺសូរស៊ែលេងស្រែកឱ្យគេជួយឈ្មោះ [redacted] ានដើរទៅមើលរួចដើរត្រឡប់មកវិញចំណែកខ្លួន [redacted] ទៅមើលទេ ។ ពេលនោះមានបុរសម្នាក់ដើរមកដោយនិយាយថាឈ្មោះ [redacted] វ៉ៃគេ ខ្លួនបានប្រកែកថា ហេតុអ្វីបានថាគាត់វ៉ៃ ។ ពីផ្ទះខ្លួនទៅកន្លែងកើតហេតុមានចំងាយប្រហែល ១០ ម៉ែត្រជាង។ ខ្លួនមិនស្គាល់មនុស្សដែលមកចោទប្រកាន់ឈ្មោះ [redacted] វាយគេទេ ។



Scanned by CamScanner

-លោកមេធាវី [redacted] បានធ្វើសេចក្តីសន្និដ្ឋានការពារកូនក្តីខ្លួនថាៈ តាមអង្គហេតុនេះបញ្ជាក់ឱ្យឃើញថាកូនក្តីខ្លួនត្រូវគេចាក់ និងកាប់ឱ្យរបួសដូចមានសំបុត្រពេទ្យបញ្ជាក់។ ឈ្មោះ [redacted] ងឈ្មោះ [redacted] ហៅ ឡុងជាជនដែដល់មានបំណងសំលាប់កូនក្តីខ្លួនតែដោយបានសាក្សីមកជួយអន្តរាគមន៍ទាន់ពេលទើបកូនក្តីខ្លួនរួចពីសេចក្តីស្លាប់ ។ ឈ្មោះ [redacted] នៅពីក្រោយខ្នង និងអ្នកបញ្ជាព្រមទាំងបានប្រតាយប្រតប់រំដោះឱ្យឈ្មោះ [redacted] គេចខ្លួនបាត់ភស្តុតាង ។

សូមកែប្រែបទចោទប៉ុនប៉ងមនុស្សឃាតវិញ ។

-លោកមេធាវី [redacted] បានធ្វើសេចក្តីសន្និដ្ឋានការពារកូនក្តីខ្លួនថាៈ ខ្លួនសូមរក្សាសេចក្តីសន្និដ្ឋានដូចសហភាគាខ្លួនផងដែរ ។ កូនក្តីខ្លួនពិតជាត្រូវបានបានជនជាប់ចោទទាំងបួននាក់ប៉ុនប៉ងសម្លាប់ដោយសារតែជនជាប់ចោទបាត់កញ្ចក់ឡានរបស់ពួកគេ ។

-តុលាការផ្អាកការសួរដេញដោលសិនដោយសារពេលវេលាម៉ោង ៦ ៣ ជាងហើយដោយបន្តសវនាការនៅព្រឹកថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១២ វេលាម៉ោង ៨៣ ព្រឹកការប្រកាសនេះទុកជាការជូនដំណឹងដើម្បីមកចូលរួមសវនាការបន្ត ។

-តុលាការប្រកាសបន្តសវនាការ

-តំណាងអយ្យការ និងមេធាវីទាំងសងខាងមិនជំទាស់នីតិវិធីអ្វីទេ ។

- <u>តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានទោសៈ</u> ឆ្លងតាមការសួរដេញដោល និងការសាកសួរសាក្សីផ្អែកទៅលើភស្តុតាង រូបថតជនរងគ្រោះក៍ដូចជាសំបុត្របញ្ជាក់របស់មន្ទីពេទ្យគឺពិតជាកើតមានអំពើហឹង្សាដែលបង្កឡើងដោយឈ្មោះ [redacted] ដែលបានចូលកាប់ ចាក់ជនរងគ្រោះទាំងពីរនាក់ឱ្យមានរបួសធ្ងន់ធ្ងរ ។ ចំណែកឈ្មោះ [redacted] ដែលឆ្លើយដោះសារថា មិនបានចូលរួមនោះពុំមានភស្តុតាងដោះបន្ទុកឡើយដោយហេតុថា សាក្សីរបស់ជនរងគ្រោះដែលនៅកន្លែងកើតហេតុជិតជាងគេបានឃើញ [redacted] បានប្រតាយប្រតប់គ្នាជាមួយអ្នកត់ម៉ូតូឌុបដែលបានទៅជួយជនរងគ្រោះ នឹងបានចាប់ឃាត់ខ្លួនជនជាប់ចោទបានផងនោះ ឱ្យជនជនជាប់ចោទរត់គេចខ្លួនបាត់ ។

មានពិរុទ្ធភាពលើជនជាប់ចោទទាំង៤នាក់ ពីបទ ហឹង្សាដោយចេតនាមានស្ថានទម្ងន់ទោសប្រព្រឹត្តនៅចំនុចផ្ទះសំណាក់បុប្ផាទីតាំងផ្ទះលេខ ២៥ ផ្លូវលេខ ៨៦ ភូមិ ២២ សង្កាត់ស្រះចក ខណ្ឌ ដូនពេញ រាជធានីភ្នំពេញកាលពីថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១២ ។

បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ។ ដោយសុំតំកល់បទចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរទុកជាបានការដដែល និងសូមឱ្យតុលាការពិនិត្យពិចារណាផ្តន្ទាទោសជនជាប់ចោទទៅតាមច្បាប់ ។

-លោកមេធាវី [redacted] មេធាវីការពារក្តីឱ្យជនជាប់ចោទឈ្មោះ [redacted] ធ្វើសេចក្តីសន្និដ្ឋានការពារកូនក្តីខ្លួនថាៈ ផ្អែកតាមអង្គហេតុឃើញថា នៅម៉ោង ០៧ និង ៣០ នាទីពិតជាមានអំពើហឹង្សាដោយចេតនាមួយកើតឡើងដោយមានការវាយតប់គ្នានៅមុខផ្ទះសំណាក់បុប្ផា ។ ឈ្មោះ [redacted] ដែលជាជនរងគ្រោះបានទៅប្តឹងប៉ូលីសថាកូនក្តីខ្លួនបានវៃគាត់ ។ កូនក្តីខ្លួនបានដើរហាត់

ប្រាណពុំបានបញ្ជាឱ្យវៃជនរងគ្រោះទេក្រោយពេលកើតហេតុទើបដឹងថាមានការវាយគ្នា ដោយពុំដឹងអ្នកណាវៃអ្នកណាទេគឺឈរនៅខាងក្រៅផ្ទះ ។ កូនក្តីខ្លួនពុំបានបញ្ជាឱ្យប្អូនប្រុសវៃជនរងគ្រោះទេ ព្រោះកំពុងឈរជាមួយសាក្សីឈ្មោះ [redacted] ។ កូនក្តីខ្លួនពុំបានចូលទៅក្នុងផ្ទះកើតហេតុនោះទេ ហើយពុំស្គាល់ជនរងគ្រោះទាំងពីរនាក់នោះទេ ។ សូមតុលាការពិចារណាដោយហេតុថា ការចោទប្រកាន់កូនក្តីខ្លួនគឺខុសមនុស្សទាំងស្រុង ដែលពុំមានភាពយុត្តិធម៌លើកូនក្តីខ្លួនឡើយ ។

-លោកមេធាវី [redacted] មេធាវីការពារក្តីឱ្យជនជាប់ចោទឈ្មោះ [redacted] បានធ្វើសេចក្តីសន្និដ្ឋានការពារកូនក្តីខ្លួនថា៖ កូនក្តីខ្លួនពុំបានតទល់ជាមួយភស្តុតាង និងសាក្សីដាក់បន្ទុកទេ ។ ភស្តុតាងថាមាន ទូលីវ៉ុស និងពូថៅពុំបានដកហូតទេ ។ ចម្លើយសាក្សី និងចម្លើយជនរងគ្រោះមិនស៊ីសង្វាក់គ្នាគឺនៅតែវិមតិសង្ស័យទាំងអស់ កូនក្តីខ្លួនជាស្ត្រីតើអាចរំដោះពីដៃអ្នករត់ម៉ូតូឌុបជាបុរសបានទេ ម៉្យាងគ្រាន់តែរឿងបាត់កញ្ចក់ឡានតិចតួចរហូតទៅហៅបងប្អូនទៅសំលាប់គេបានទេ សូមតុលាការពិចារណា ។

-លោកមេធាវី [redacted] មេធាវីការពារក្តីឱ្យជនជាប់ចោទឈ្មោះ [redacted] ឈ្មោះ [redacted] បានធ្វើសេចក្តីសន្និដ្ឋានការពារកូនក្តីខ្លួនថា៖ កូនក្តីខ្លួនពុំមានចេតនាប្រព្រឹត្តទេ ដោយហេតុថាមិននៅកន្លែងកើតហេតុមានសាក្សីឈ្មោះ [redacted] បញ្ជាក់នៅជាមួយគ្នាដោយឈរជជែកពីរឿងដីធ្លីទេ ពុំមានទាក់ទងនឹងអង្គហេតុមានចេតនាក្នុងរឿងហឹង្សាទេ។ ពុំមានសាក្សីណាមួយក្រៅពីឪពុកជនរងគ្រោះបានឃើញ និងបញ្ជាក់ថាកូនក្តីខ្លួនជាអ្នកចាប់ទាញដៃឱ្យជនជាប់ចោទរត់គេចខ្លួននោះទេ ។ វត្តមានកូនក្តីខ្លួននៅកន្លែងកើតហេតុដោយចៃដន្យបំផុតព្រោះថា កូនក្តីខ្លួនម្នាក់ថាចេញក្រៅថាទិញអីហូបបងម្នាក់ទៀតទៅហាត់ប្រាណពុំទាក់ទងនឹងអំពើហឹង្សាទេ ។ វត្តមានកូនក្តីខ្លួននៅកន្លែងកើតហេតុពុំមែនជាភស្តុតាងដាក់បន្ទុកទេ ។ ការចោទប្រកាន់កូនក្តីខ្លួននោះគឺខុសមនុស្សហើយផ្អែកតាមមាត្រា ២៨៧ នៃក្រមព្រហ្មទណ្ឌអ្នកណាប្រព្រឹត្តអ្នកនោះទទួលខុសត្រូវពុំអាចចាប់កូនក្តីខ្លួនឱ្យទទួលកំហុសជាមួយអ្នកដទៃទេ ។ ផ្អែកតាមមាត្រា៨នៃក្រមព្រហ្មទណ្ឌកូនក្តីខ្លួនពុំមានចេតនាប្រព្រឹត្តទេ ។

ចម្លើយសាក្សីសំខាន់បីនាក់ឈ្មោះ [redacted] ជាចម្លើយមានវិមតិសង្ស័យព្រោះថាសាក្សីនេះពុំមែនជាសមត្ថកិច្ចមូលដ្ឋានផងហេតុអ្វីបានជាស្គាល់អត្តសញ្ញាណជនជាប់ចោទច្បាស់ម្លេះពេលឆ្លើយនៅក្នុងកំណត់ហេតុពោលស្គាល់តាំងពីត្រកូល ឈ្មោះ អាយុ ។ សាក្សីថាបានឃើញទូលីវ៉ុសដងខៀវ យប់ងងឹតម៉ោង ប្រាំពីរ ហេតុអ្វីមើលស្គាល់ គឺជាចម្លើយបុរេវិនិច្ឆ័យរបស់សាក្សីមុនប៉ុណ្ណោះ ។ សាក្សីពុំមានវត្តមាននៅកន្លែងកើតហេតុទេ ចម្លើយសាក្សីឈ្មោះ [redacted] គឺឆ្លើយតាមការនឹកឃើញតែប៉ុណ្ណោះ ។ សាក្សីឈ្មោះ [redacted] គឺជាឪពុក និងពូរបស់ជនរងគ្រោះមកធ្វើជាសាក្សីឱ្យគាត់មានទំនាស់ផលប្រយោជន៍ ។ ការឃើញរបស់គាត់មានភាពស្រពិចស្រពិលព្រោះថាម្តងគាត់ ជាអ្នកចាប់ឈ្មោះ [redacted] ម្តងគាត់ថាចាប់ឈ្មោះ [redacted] ជាមួយអ្នករត់ម៉ូតូឌុបជាចម្លើយខុសគ្នាមិនអាចដាក់បន្ទុកកូនក្តីខ្លួនបានទេ ។ ចម្លើយរបស់ដើមបណ្តឹងទាំងពីរនាក់រាពជា ចម្លើយដែលជាមនុស្សស្ថិតក្នុងភាពស្រវឹងដោយភ័នស្មារតី

ខ្លួនសុំបដិសេធចម្លើយដើមបណ្តឹងទាំងពីររូបនេះ ។ វិមតិសង្ស័យត្រូវបានប្រយោជន៍ដល់កូនក្តីខ្លួនសូមលើកលែងបទចោទលើកូនក្តីខ្លួន និងសុំបដិសេធសំណងការទាមទាររបស់ដើមបណ្តឹង ។ ការលើកឡើងរបស់មេធាវីជនរងគ្រោះសូមឱ្យកែប្រែបទចោទ ប៉ុនប៉ងមនុស្សឃាតលើកូនក្តីខ្លួននោះគឺពុំអាចទៅរួចទេ ។ សំណូមពរសូមលើកលែងការចោទប្រកាន់ និងដោះលែងកូនក្តីខ្លួនឱ្យបានទៅរស់នៅជួបជុំក្រុមគ្រួសារធ្វើជាពលរដ្ឋវិញ ។ ចម្លើយសាក្សីមិនច្បាស់លាស់ជាមួយ និងចម្លើយជនរងគ្រោះ សូមឱ្យពិនិត្យពិចារណាចម្លើយសាក្សី ឈ្មោះ[redacted]និងចម្លើយសាក្សីរងគ្រោះ ។

-លោកមេធាវី[redacted]ជាមេធាវីការពារក្តីឱ្យជនរងគ្រោះបានធ្វើសេក្តីសន្និដ្ឋានតបថា: ពិតជាមានអំពើកើតឡើង ហើយចំពោះអង្គហេតុទាំងមូលនោះ មានសាក្សីបញ្ជាក់ច្បាស់រួចហើយថា ឈ្មោះ [redacted] បានចាប់ប្រលេះដៃពីអ្នកដែលចាប់ប្អូនខ្លួនបានឱ្យរត់ ។ ចម្លើយសាក្សីជាចម្លើយពិតប្រាកដមានវត្តមាននៅកន្លែងកើតហេតុមិនមែនជាចម្លើយវិមតិសង្ស័យអ្វីនោះទេ មិនអាចបដិសេធចម្លើយសាក្សីបានឡើយ ។ កូនក្តីខ្លួនស្រវឹងនៅដឹងខ្លួនមិនបាត់បង់ស្មារតីទេ សូមតុលាការពិចារណា ។

លោកមេ[redacted]ជាមេធាវីការពារក្តីឱ្យជនរងគ្រោះបានធ្វើសេចក្តីសន្និដ្ឋានបន្តថា: រឿងកើតឡើងមានហេតុទើបមានបច្ច័យអ្នកស្រី[redacted]បានបាត់កញ្ចក់ឡានគាត់មានការសង្ស័យទៅលើកូនក្តីខ្លួនទាំងពីរនាក់ទើបគាត់ប្រាប់បងប្អូនរបស់គាត់ទាំងពីរនាក់រួចបានមកប៉ងសំលាប់កូនក្តីខ្លួនទាំងពីរនាក់ តែដោយសារមានការជួយអន្តរាគមន៍ទាន់ទើបបានរួចជីវិត ។ ចម្លើយ [redacted]ជាចម្លើយច្បាស់លាស់ថា ឈ្មោះ[redacted]កកាប់ចាក់ពួកខ្លួន ទោះបីចម្លើយឈ្មោះ [redacted]ន ច្បាស់លាស់ក៏ដោយតែក៏បានបញ្ជាក់ច្បាស់លាស់ថា មានមនុស្សប្រុសពីរនាក់មកកាប់ចាក់ពួកខ្លួន ។ ចំណែកឈ្មោះ [redacted]ក៏ជាអ្នករួមគំនិតបញ្ជាឱ្យបងប្អូនទាំងពីរនាក់ប្រព្រឹត្តថែមទាំងចាប់ប្រលេះដៃឱ្យប្អូនរត់គេចខ្លួនថែមទៀត ។ សាក្សីឈ្មោះ[redacted]បានបញ្ជាក់ថាឈ្មោះ[redacted]ានដើរទៅកន្លែងកើតហេតុបន្ទាប់មកទើបដើរត្រឡប់មកផ្ទះរបស់គាត់វិញ ។ ជនរងគ្រោះឈ្មោះ[redacted]នៅមានស្មារតីមិនមែនស្រវឹងមិនដឹងខ្លួនទេព្រោះគាត់ដល់ម៉ោងឈប់រត់ឌុបម៉ូយទើបមកផឹកស្រា ។

-ជនជាប់ចោទឈ្មោះ[redacted] បានឆ្លើយសំដីចុងក្រោយរបស់ខ្លួនថា: ខ្លួនជាស្ត្រីភេទខ្លួនពុំបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ខ្លួនពុំដែលស្គាល់ជនរងគ្រោះ និងសាក្សីនោះទេ ម្យ៉ាងទៀតពេលកើតហេតុ ហេតុអ្វីមិនចាប់រូបខ្លួនភ្លាមហេតុរំលងមួយខែទើបមកចាប់រូបខ្លួន ។ ប៉ូលីសប៉ុស្ត៍ពុំបានហៅខ្លួនទៅសាកសួរទេ នេះគឺជាល្បិច ។ សូមឱ្យតុលាការទំលាក់ការចោទប្រកាន់រូបខ្លួន សូមទៅជួបជុំក្រុមគ្រួសារវិញ ។

-ជនជាប់ចោទឈ្មោះ[redacted]ានឆ្លើយសំដីចុងក្រោយរបស់ខ្លួនថា: ខ្លួនពុំបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ជនរងគ្រោះឆ្លើយថា ពុំមានអ្នកណានៅកន្លែងកើតហេតុទេ ហើយក៏ពុំចាប់បានអ្នកប្រព្រឹតមកចង្អុលបង្ហាញថាខ្លួនជាអ្នកបញ្ជាទេ ខ្លួនពុំស្គាល់ជនរងគ្រោះ និងសាក្សីទាល់តែសោះ ។ សូមតុលាការលើលែងការចោទប្រកាន់ ។



Scanned by CamScanner

-ក្រោយពីបាន ស្តាប់ការសួរដេញដោលជនជាប់ចោទឈ្មោះ [redacted]

-ក្រោយពីបាន ស្តាប់ចម្លើយជនរងគ្រោះទាំងពីរនាក់

-ក្រោយពីបានស្តាប់ ចម្លើយសាក្សី

-ក្រោយពីបាន ពិនិត្យលើកំណត់ហេតុ ឯកសារភស្តុតាងនានាធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌,ថៅក្រមស៊ើបសួរ,អយ្យការ ។

-ក្រោយពីបានស្តាប់ សេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីជនរងគ្រោះ។

-ក្រោយពីបានស្តាប់ សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់ សេចក្តីសន្និដ្ឋានរបស់មេធាវីជនជាប់ចោទឈ្មោះ [redacted]

-ក្រោយពីបានស្តាប់ សំដីចុងក្រោយរបស់ជនជាប់ចោទទាំងពីរនាក់ ។

-សាលាដំបូងរាជធានីភ្នំពេញ បានពិចារណាត្រឹមត្រូវតាមច្បាប់ហើយយល់ឃើញថា៖

<u>សំអាងហេតុ:</u>

១/ពិតជាកើតមានអំពើល្មើសបទៈ ហឹង្សាដោយចេតនា មានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅមុខ ផ្ទះសំណាក់បុប្ផា ទីតាំងផ្ទះលេខ ៥ ផ្លូវ ៨៦ ភូមិ ២២ សង្កាត់ ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១២ ដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] ភេទ ស្រី អាយុ ២៩ ឆ្នាំ ជាតិ ខ្មែរ , ឈ្មោះ [redacted] ភេទ ប្រុស អាយុ ៥៦ ឆ្នាំ ជាតិ ខ្មែរ [redacted] ភេទ ប្រុស អាយុ ៣០ ឆ្នាំ ជាតិ ខ្មែរ និងឈ្មោះ [redacted] ភេទ ប្រុស អាយុ ២៧ ឆ្នាំ ជាតិ ខ្មែរ ប្រាកដមែន ។

២/រាល់សកម្មភាពនៃអំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] ភេទ ស្រី អាយុ ២៩ ឆ្នាំ ជាតិ ខ្មែរ , ឈ្មោះ [redacted] ភេទ ប្រុស អាយុ ៥៦ ឆ្នាំ ជាតិ ខ្មែរ , ឈ្មោះ [redacted] ភេទ ប្រុស អាយុ ៣០ ឆ្នាំ ជាតិ ខ្មែរ និងឈ្មោះ [redacted] ភេទ ប្រុស អាយុ ២៧ ឆ្នាំ ជាតិ ខ្មែរ ស្ថិតនៅទីកន្លែងនិងពេលវេលាដូចខាងលើ គឺមានធាតុផ្សំគ្រប់គ្រាន់ជាបទ ហឹង្សាដោយចេតនា មានស្ថានទម្ងន់ទោស ដូចមានចែងឲ្យផ្តន្ទាទោសតាមបទបញ្ញត្តិ មាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ។

៣/ជនជាប់ចោទឈ្មោះ [redacted] ភេទ ស្រី អាយុ ២៩ ឆ្នាំ ជាតិ ខ្មែរ , ឈ្មោះ [redacted] ភេទ ប្រុស អាយុ ៥៦ ឆ្នាំ ជាតិ ខ្មែរ , ឈ្មោះ [redacted] ភេទ ប្រុស អាយុ ៣០ ឆ្នាំ ជាតិ ខ្មែរ និងឈ្មោះ [redacted] ភេទ ប្រុស អាយុ ២៧ ឆ្នាំ ជាតិ ខ្មែរ គឺពួកគេសុទ្ធតែជាសមត្ថជន មានស្មារតីជានាល្អ មានសតិបញ្ញាល្អ យល់ដឹងគ្រប់គ្រាន់ពី អំពើប្រព្រឹត្តរបស់ខ្លួន អាចកើតមានព្យសនកម្មប៉ះពាល់ដល់រូបរាងកាយរបស់ជនរងគ្រោះនិងបំពារបំពានខុសនឹងបទបញ្ញត្តិនៃច្បាប់ ព្រហ្មទណ្ឌកំពុងជាធរមាន ។ ប៉ុន្តែផ្ទុយទៅវិញពួកគេទាំងបួននាក់នៅតែមានគំនិតចេតនា ដោយទុច្ចរិតលូកដៃ ប្រព្រឹត្តបទល្មើសយ៉ាងសកម្មរហូតដល់សំរេចផលជាក់ស្តែងតាមអង្គ ហេតុបង្ហាញអោយឃើញថា៖ កាលពីថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១២ នៅវេលាម៉ោង ប្រហែលជា ១៩ និង ៣០ នាទី នៅចំនុចមុខ ផ្ទះសំណាក់បុប្ផា ទីតាំងផ្ទះលេខ ៥ ផ្លូវ ៨៦ ភូមិទី ២២ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ



Scanned by CamScanner

ឈ្មោះ [redacted] ភេទ ស្រី អាយុ ២៩ ឆ្នាំ ជាតិ ខ្មែរ , ឈ្មោះ [redacted] ភេទ ប្រុស អាយុ ៥៦ ឆ្នាំ ជាតិ ខ្មែរ បាននាំបងប្អូនឈ្មោះ [redacted] ភេទ ប្រុស អាយុ ៣០ ឆ្នាំ ជាតិ ខ្មែរ និងឈ្មោះ [redacted] ភេទ ប្រុស អាយុ ២៧ ឆ្នាំ ជាតិ ខ្មែរ បានដើរសំដៅទៅរក ជនរងគ្រោះឈ្មោះ [redacted] ភេទ ប្រុស អាយុ ២៤ ឆ្នាំ និង ឈ្មោះ [redacted] ហៅ [redacted] ភេទ ប្រុស អាយុ ២៦ ឆ្នាំ ដែលគេជាអ្នករត់ម៉ូតូឌុប កំពុងរង់ចាំដឹកម៉ូយនៅចំនុចកើតហេតុ ខាងលើ នៅពេលពួកគេជនជាប់ចោទទៅដល់ឈ្មោះ [redacted] ដែលមាន ទូលីវិស និងដៃ បានចាប់គ្រៀកកជនរងគ្រោះឈ្មោះ [redacted] ហើយយកទូលីវីសចាក់ លើក្បាលបណ្តាលឲ្យទទួលរងរបួសជាច្រើនកន្លែង និងចាក់ត្រង់ខ្នងចំបោះដៃផុតចំនួន ១ កន្លែងទៀត ។ រីឯឈ្មោះ [redacted] បានយកពូថៅកាប់ទៅលើឈ្មោះ [redacted] ចំក្បាល បណ្តាលឲ្យទទួលរងរបួសចំនួន ០២ កន្លែងបណ្តាលហូរឈាមយ៉ាងខ្លាំងទន្ទឹមគ្នានោះ ឪពុកបង្កើតរបស់ឈ្មោះ [redacted] រួមជាមួយអ្នកជិតខាងបានចូលជួយធ្វើអន្តរាគមន៍ ឃាត់ចាប់ជនជាប់ចោទឈ្មោះ [redacted] តែត្រូវជនជាប់ចោទឈ្មោះ [redacted] ជាបង ស្រី បង្កើតរបស់ឈ្មោះ [redacted] និងប្តីបានឈរបញ្ចា និងបានចូលជួយប្អូនខ្លួនដោយ រំដោះប្អូនឲ្យរួចរត់គេចខ្លួនបាត់អស់តែម្តង ។ លុះនាថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១២ ឈ្មោះ [redacted]វបានឃាត់ខ្លួនតាមដីកាបង្គាប់ឲ្យនាំខ្លួនលេខ: ៣២៨ តព្រ និង ៤២៩ តព្រ របស់ចៅក្រមស៊ើបសួរ សាលាដំបូងរាជធានីភ្នំពេញ តែជនជាប់ចោទពីរនាក់ផ្សេងៗទៀតកំពុងរត់គេចខ្លួនរហូតសព្វថ្ងៃ ។

៤/ពិតជាមាន<u>ភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទ</u>ឈ្មោះ [redacted] ភេទ ស្រី អាយុ ២៩ ឆ្នាំ ជាតិ ខ្មែរ , ឈ្មោះ [redacted] ភេទ ប្រុស អាយុ ៥៦ ឆ្នាំ ជាតិ ខ្មែរ , ឈ្មោះ [redacted] ហៅ [redacted] ភេទ ប្រុស អាយុ ៣០ ឆ្នាំ ជាតិ ខ្មែរ និងឈ្មោះ [redacted] ភេទ ប្រុស អាយុ ២៧ ឆ្នាំ ជាតិ ខ្មែរ <u>ពីបទ:</u> ហិង្សាដោយចេតនា មានស្ថានទម្ងន់ទោស ប្រព្រឹត្តស្ថិតនៅទីកន្លែង និងពេលវេលាដូចការចោទប្រកាន់ខាងលើប្រាកដមែន ។

<u>ភស្តុតាងរួមមាន៖</u>

-ផ្អែកតាមចំលើយឲ្យ ការដាក់បន្ទុករបស់ដើមបណ្តឹងនិងជាជនរងគ្រោះឈ្មោះ [redacted] នៅពេលសវនាការក៏ដូចនៅសមត្ថកិច្ចនគរបាល , នៅអយ្យការ និងនៅចៅក្រមស៊ើបសួរឆ្លើយប្រហាក់ប្រហែលគ្នាថា៖ នៅយប់ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១២ វេលាម៉ោងប្រហែល ១៩ និង ៣០ នាទី ពេលខ្លួនកំពុងអង្គុយចាំម៉ូយនៅចំនុចមុខ ផ្ទះសំណាក់បុប្ផា ទីតាំងផ្ទះលេខ ៥ ផ្លូវ ៨៦ ភូមិ ២២ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ស្រាប់តែឈ្មោះ [redacted] និងប្តីមិនស្គាល់ឈ្មោះ បាននាំបងប្អូនឈ្មោះ [redacted] និងឈ្មោះ [redacted]កចង្អុលមុខខ្លួននិងមិត្តភក្រ័ខ្លួនឈ្មោះ [redacted] ដោយចោទប្រកាន់ថាបានលួចកាច់កញ្ចក់រថយន្តភ្លាមនោះឈ្មោះ [redacted] ដែលមាន កាន់ទូលីវិស នៅនិងដៃបានចាក់មកលើក្បាលខ្លួនបណ្តាលឲ្យរងរបួស ០៤ កន្លែង និងត្រង់ខ្នងបោះដៃផុតចំនួន ០១ កន្លែងទៀត ហូរឈាមយ៉ាងខ្លាំង ចំណែកឯឈ្មោះ [redacted] បានយកពូថៅកាប់ទៅលើមិត្តភក្រ័ខ្លួនឈ្មោះ [redacted] បណ្តាលឲ្យរបួសច្រើន កន្លែងហូរឈាមយ៉ាងខ្លាំង ។ ទន្ទឹមគ្នានោះឪពុកខ្លួនបានទៅជួយទើបឈ្មោះ [redacted] បងរត់ទៅក្រៅ

Scanned by CamScanner

តែត្រូវពួរត់ម៉ូតូឌុបម្នាក់ឈ្មោះ [redacted] ាប់តែត្រូវឈ្មោះ [redacted] ទៅប្រតាយប្រតប់គ្នាជាមួយអ្នករត់ម៉ូតូឌុបនោះ ដើម្បីជួយឲ្យ [redacted] សិទ្ធ រត់គេចខ្លួនហើយឈ្មោ [redacted] ានស្រែកថាឲ្យប្អូនខ្លួនវាយចោរលួចកញ្ចក់រថយន្ត ។ ក្រោយពេលកើតហេតុភ្លាមៗឪពុកខ្លួនបាននាំទៅព្យាបាលស្នាម របួសនៅមន្ទីរពេទ្យកាល់ម៉ែត្រអស់រយៈពេលពីរថ្ងៃ។ ខ្លួនពិតជាស្គាល់យ៉ាងច្បាស់លាស់អំពីអត្តសញ្ញាណជនជាប់ចោទទាំងបួននាក់ខាងលើនេះព្រោះថា ពួកគាត់មានផ្ទះជាទីលំនៅជិតគ្នាផ្ទះដែលខ្លួនបានជួលរស់នៅរយៈពេល បីឆ្នាំមកហើយ ហើយខ្លួនពុំធ្លាប់មានទំនាស់អ្វីជាមួយភាគីជនជាប់ចោទទាំងបួននាក់នេះទេ ។ ម្យ៉ាងទៀតនៅកន្លែងកើតហេតុគឺមានភ្លើងអគ្គីសនីភ្លឺច្បាស់អាច មើលឃើញគ្នាស្គាល់យ៉ាងពិតប្រាកដ ។ តាមចំលើយរបស់ឈ្មោ [redacted] ដូចខាង លើគឺមានភាពស៊ីចង្វាក់គ្នាយ៉ាងខ្លាំងទៅ និងចំលើយឲ្យការដាក់បន្ទុកដើមបណ្តឹងជាជនរងគ្រោះឈ្មោះ [redacted] បានឆ្លើយឲ្យការនៅសមត្ថកិច្ចនគរបាលយុត្តិធម៌ នៅអយ្យការ នៅចៅក្រមស៊ើបសួរ ជាពិសេសពេលសវនាការប្រហាក់ប្រហែលគ្នាថាៈ នៅថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១២ ប្រហែលវេលាម៉ោង ១៩ និង ៣០ នាទី ខ្លួនបានដើរទៅអង្គុយលេងដោយហូបស្រាជាមួយឈ្មោះ [redacted] នៅចំនុចមុខ ផ្ទះសំណាក់បុប្ផា ទីតាំងផ្ទះលេខ ៥ ផ្លូវ ៨៦ ភូមិ ២២ សង្កាត់ស្រះចក ខណ្ឌដូនពេញ នៅកន្លែងនោះមានភ្លើងភ្លឺច្បាស់អាចមើលគ្នាស្គាល់ស្រាប់តែឈ្មោះ [redacted] ង ឈ្មោ [redacted] ដែលមាន កាន់ពូថៅ និងទូលីវែស នៅនឹងដៃពេលមកដល់ឈ្មោ [redacted] បានចង្អុលមកខ្លួន និងឈ្មោះ [redacted] បានចោទប្រកាន់ថាពួកខ្លួនបានលួចកញ្ចក់រថយន្តរបស់គាត់ភ្លាម នោះឈ្មោះ [redacted] បានយកពូថៅស្ទុះមកកាប់លើក្បាលខ្លួនបណ្តាល ឲ្យត្រូវចំហៀងក្បាលផ្នែកខាងឆ្វេង រីឯឈ្មោះ [redacted] ានយក ទូលីវែស ចាក់ទៅ លើពួកម៉ាកខ្លួនឈ្មោះ [redacted] ។ ក្រោយមកឃើញឪពុករបស់ឈ្មោ [redacted] មកដល់គាត់ជួយចាប់ចេញទើបអ្នកទាំងពីរនាក់ឈប់កាប់ចាក់មកលើពួកខ្លួនទាំងពីរនាក់ ហើយរត់គេចខ្លួនបាត់តែម្តងចំពោះឈ្មោះ [redacted] មកជួយអន្តរាគមន៍ឲ្យប្អូនរត់គេចខ្លួន រីឯប្តីគាត់ឈរជិតពុំបានធ្វើសកម្មភាពទេហើយអ្នកទាំងពីរនាក់ប្តីប្រពន្ធ ពួកគាត់ពុំ ទាន់រត់គេចទៅណាទេ កំពុងនៅជជែកគ្នាជាមួយអ្នករត់ម៉ូតូឌុប ដែលមកជួយចាប់ជនល្មើស នៅកន្លែងកើតហេតុ ។ ខ្លួនពុំដែលធ្លាប់មានទំនាស់ជាមួយភាគីជនជាប់ចោទទេ ។

-តាមចំលើយដើមបណ្តឹងជាជនរងគ្រោះឈ្មោះ [redacted] និងឈ្មោ [redacted] ដូចខាងលើឃើញថា មានភាពស៊ីចង្វាក់គ្នាយ៉ាងខ្លាំងទៅ និងចំលើយឲ្យការបញ្ជាក់របស់សាក្សីឈ្មោ [redacted] ានឆ្លើយនៅដំណាក់កាល មន្ត្រីនគរបាលយុត្តិធម៌ នៅអយ្យការ នៅចៅក្រមស៊ើបសួរក៏ដូចនៅពេលសវនាការ ប្រហាក់ប្រហែលគ្នាថាៈ នាថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១២ វេលាម៉ោង ១៩ និង ១០ នាទី ខ្លួនកំពុងអង្គុយនៅមុខផ្ទះសំណាក់ស្វស្តី ពេលនោះក៏មានក្មេងរត់ឆោឡោ ហើយមកប្រាប់ថាមានគេព្រួតវាយកូនខ្ញុំឈ្មោះ [redacted] សេង ពេលនោះខ្លួនក៏បានទៅដល់មុខផ្ទះលេខ ៥ គឺផ្ទះសំណាក់បុប្ផា ពេលនោះខ្ញុំឃើញឈ្មោះ [redacted] ប្រើប្រាស់ទូលីវែស មុខបួនចាក់មកលើកូនខ្ញុំ ត្រូវចំនុចក្បាលជាច្រើនដង ចំណែកឈ្មោះ [redacted] បានកាន់ពូថៅតំរាមខ្ញុំថាបើហ៊ានចូលប្រយ័ត្នកាប់ចោល



Scanned by CamScanner

ពេលនោះខ្ញុំដើរចូលជិតក៏ ប្រតាយប្រតប់គ្នាហើយឈ្មោះ[redacted]ហាកអាវបេសិ៍ របស់វា ហើយវាបានយកអាវរុំពូថៅរត់គេច តែត្រូវអ្នករត់ម៉ូតូឌុបឈ្មោះ[redacted] ជួយចាប់ជាប់ ប៉ុន្តែមានឈ្មោះ[redacted]បងស្រីបង្កើតនិងប្តីបានជួយទាញដៃអោយប្អូន ខ្លួនរត់គេចខ្លួនបាត់តែម្តង ។ ទន្ទឹមគ្នានោះឈ្មោ[redacted]បាននិយាយថាអាញ់មាន បំណងចង់សំលាប់វាចោលហើយខ្លួនក៏ឈប់មាត់ទៅ ប្រញាប់យកកូនឈ្មោះ[redacted] និងម្នាក់ទៀយឈ្មោះ[redacted]ទៅមន្ទីរពេទ្យកាលម៉ែត្រដើម្បីព្យាបាលរបួស ។ ព្រឹកឡើង ថ្ងៃបន្ទាប់ទើបនាំកូននិងក្មួយទៅដាក់ពាក្យបណ្តឹងនៅប៉ុស្តិ៍ប៉ូលីសរដ្ឋបាលស្រះចក ។ នៅ កន្លែងកើតហេតុគឺមានភ្លើងអគ្គីសនី ភ្លឺច្បាស់ចាំងពីផ្ទះសំណាក់បុប្ផា ចំពោះឈ្មោះ[redacted]ខ្លួនស្គាល់ច្បាស់ព្រោះផ្ទះនៅជិតផ្ទះខ្លួនដែរ ។

-ចំលើយឲ្យការបញ្ជាក់របស់ឈ្មោះជនរងគ្រោះឈ្មោ[redacted]ងចម្លើយរបស់សាក្សីឈ្មោ[redacted]ចបានរៀបរាប់ចំនុចខាងលើគឺមានភាព ស៊ីចង្វាក់គ្នាយ៉ាងខ្លាំងទៅនឹងចំលើយឲ្យការបញ្ជាក់របស់សាក្សីឈ្មោះ [redacted]ភេទ ប្រុស អាយុ ៤២ នៅគ្រប់ដំណាក់កាលដូចជានៅមន្ត្រីនគរបាលអយ្យការ ចៅក្រមស៊ើបសួរ ជាពិសេសនៅពេលសវនាការបានឆ្លើយប្រហាក់ប្រហែលគ្នាថាៈនៅថ្ងៃមិនចាំក្នុងខែ សីហា ឆ្នាំ ២០១២ វេលាម៉ោងប្រហែលជា ៥ ល្ងាច ជាងខ្លួនទៅអង្គុយចាំម៉ូយនៅមុខផ្ទះសួរស្តី កំពុងអង្គុយជជែកគ្នាជាមួយអ្នករត់ម៉ូតូឌុបដូចគ្នា មួយសន្ទុះនៅមុខផ្ទះសំណាក់សួស្តីស្រាប់ តែឮសូរប្រោវនៅក្នុងផ្ទះសំណាក់បុប្ផា ដែលមានចំងាយប្រហែល ២០ ម៉ែត្រ មួយសន្ទុះ ក្រោយមកស្រាប់តែមានក្មេងម្នាក់រត់ចេញមកដល់ កន្លែងខ្លួនអង្គុយស្រែកប្រាប់ថាទៅជួយ [redacted]ងគេកាប់ងាប់ហើយពេលនោះឪពុកជនរងគ្រោះរត់ទៅមុខខ្លួន ហើយ ខ្លួនរត់ទៅក្រោយ ពេលទៅដល់ឪពុកជនរងគ្រោះបានចូលទៅទាញកូនចេញ ហើយ ស្រែក ថាម៉េចធ្វើបាបកូនខ្ញុំអញ្ចឹង ។ ពេលនោះខ្ញុំឃើញជនម្នាក់កំពុងតែចាប់គាបករ ជនរងគ្រោះ ឈ្មោះ[redacted] ហើយយក ទូលីវីស បុកពីលើក្បាលជនរងគ្រោះ រីឯជនដៃដល់ ម្នាក់ទៀតកំពុង តែ [redacted] ជនរងគ្រោះម្នាក់ទៀតនៅខាងក្នុង ខ្លួនពុំឃើញផ្ទាល់ភ្នែកទេប៉ុន្តែ ពេលជនដៃដល់ នោះដើរចេញមកខាងក្រៅ មានអ្នកស្រែកអោយជួយចាប់ឃាតករផងតែ ប្រយ័ត្នវាមាន ពូថៅ ទន្ទឹមគ្នានោះខ្លួនបានចាប់ឈ្មោះ[redacted]ជាប់តែគឺមានបង ស្រីបងប្រុសរបស់ ជនដៃដល់ ជួយប្រតាយប្រតប់បេះដៃ ឲ្យជនដៃដល់ដើម្បីរត់គេចខ្លួន ហើយបងស្រីនោះ ស្រែកថាពួងឯកុំចេះគេមកវ៉ៃតែអា ចោរលួចកាច់កញ្ចក់ឡានទេខ្ញុំស្គាល់ [redacted] និងឈ្មោ[redacted]ាស់ព្រោះពួកគេធ្លាប់ជិះម៉ូតូឌុបខ្លួន ជាញឹកញាប់ទៀតផង ។ ចំលើយឲ្យការទាំងនេះមានភាពស៊ីចង្វាក់គ្នាផងដែរទៅនឹង ចម្លើយសាក្សីឈ្មោះ [redacted] ភេទ ស្រី អាយុ ១៩ ឆ្នាំ បានឆ្លើយនៅដំណាក់កាល នគរបាលយុត្តិធម៌ អយ្យការ ចៅក្រម ស៊ើបសួរ និងនាពេលសវនាការ ប្រហាក់ប្រហែល គ្នាថាៈ នៅថ្ងៃកើតហេតុខាងលើ ខ្លួន កំពុងអង្គុយហូបបាយនៅ ផ្ទះសំណាក់បុប្ផា ខណៈ ពេលជនរងគ្រោះឈ្មោ[redacted]កំពុងតែអង្គុយផឹកស្រានៅក្នុង ផ្ទះសំណាក់បុប្ផា នេះដែរស្រាប់តែមានមនុស្សពីរនាក់គឺ ស្រីមួយប្រុសមួយដើរចូលមកផ្ទះ សំណាក់ហើយឃើញជជែកគ្នាជាមួយជនរងគ្រោះទាំង ពីរនាក់ តែពុំដឹងថានិយាយពីអ្វីទេ ហើយអ្នកទាំងពីរនាក់នោះដើរចេញក្រៅទៅ ស្រាប់តែ

ឃើញមនុស្សប្រុសពីរនាក់ទៀតដើរ ចូលមកសួរមនុស្សស្រីមួយប្រុសមួយដែលដើរចូលមកមុន ហើយមនុស្សពីរអ្នកមុនប្រាប់ថា ហ្នឹងហើយអាចោរកាច់កញ្ចក់ឡាន ។ ពេលដែលមនុស្សពីរនាក់ជាជនដៃដល់សួរមនុស្ស ស្រីនោះរួចហើយក៏ចូលមកវាយឈ្មោះ [redacted] ប៉ុន្តែឈ្មោះ [redacted] ក៏ចូលទៅជួយកំព្រូវ ជនដៃដល់ម្នាក់ទៀតចាប់ឈ្មោះ [redacted] កទៅវាយដែរ ចំពោះឈ្មោះ [redacted] ត្រូវគេចាក់និង ទួឈើវែស និងឈ្មោះ [redacted] ត្រូវគេកាប់ ។ ពេលឃើញដូចច្នេះខ្លួនក៏រត់ចេញទៅប្រាប់ ឪពុករបស់ឈ្មោះ [redacted] ឲ្យមកកន្លែង កើតហេតុដើម្បីជួយកូនគាត់ ។ ស្របពេលនោះឪពុក ជនរងគ្រោះរត់ទៅដល់ពុំហ៊ានចូលទេព្រោះជនដៃដល់ស្រែកថាមានកាំភ្លើង ។ នាងខ្ញុំឃើញពូម៉ូតូឌុបម្នាក់បានចាប់ជនដៃដល់ម្នាក់ជាប់តែឃើញ មនុស្សស្រីម្នាក់មកប្រតាយ ប្រតប់ចាប់ប្រទ្បេះដៃពូម៉ូតូឌុបចេញ ឲ្យជនដៃដល់រត់គេចខ្លួនទន្ទឹមគ្នានោះស្រីនោះបានស្រែកថាអាឡុងម៉េចមិនរត់ទៅស្របពេលនោះជនដៃដល់ក៏រត់គេចទៅ ។

-ចម្លើយឲ្យការបញ្ជាក់របស់ជនរងគ្រោះទាំងពីរនាក់ [redacted] , ឈ្មោះ [redacted] ភេទប្រុស អាយុ ៤២ ឆ្នាំ បានរៀបរាប់ចំនុចខាងលើ គឺមានភាពស៊ីសង្វាក់គ្នាទៅនិងភស្តុតាងសំបុត្រពេទ្យមន្ទីរពេទ្យកាល់ម៉ែត្រ ដូចជា បណ្ណ័បញ្ជាបង់ប្រាក់ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១២ របស់គ្រូពេទ្យព្យាបាលរោគវិនិច្ឆ័យ Tel qurrette ព្រមទាំងវិក័យប័ត្រព្យាបាលជម្ងឺរបស់មន្ទីរពេទ្យកាល់ម៉ែត្រ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១២ បញ្ជាក់ពីស្នាមរបួសរបស់ជនរងគ្រោះទាំងពីរនាក់ ទទួលរងពីអំពើល្មើសដែលបង្ករឡើង ដោយជនជាប់ចោទទាំងបួននាក់រួមគំនិតគ្នាប្រព្រឹត្ត , ក៏ស៊ីសង្វាក់គ្នាផងដែរនឹងរូបថតស្នាម របួសលើជនរងគ្រោះទាំងពីរនាក់ ធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌ ។ លើសពីនេះ ទៀតគឺមានលក្ខណៈសមស្របយ៉ាងខ្លាំងទៅនឹងព្រឹត្តហេតុ , ហេតុការណ៍នឹងកាលៈទេសៈ នៃបទល្មើសដូចក្នុងរបាយការណ៍សំយោគលេខ: ១១៣ របក ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១២ របស់អធិការដ្ឋាននគរបាល ខណ្ឌដូនពេញ នៃស្នងការដ្ឋាននគរបាល រាជធានី ភ្នំពេញ បានបញ្ជាក់យ៉ាងច្បាស់លាស់ថា៖ នៅថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១២ វេលាម៉ោង ១៩ និង ៣០ នាទី ស្ថិតនៅទីកន្លែងនិងពេលវេលាដូចខាងលើគឺពិតជាកើតមានករណី <u>បទ:</u> អំពើហិង្សាដោយចេតនា មានស្ថានទម្ងន់ទោស ដែលបង្កឡើងដោយ ជនជាប់ចោទ ឈ្មោះ [redacted] ភេទ ស្រី អាយុ ២៩ ឆ្នាំ ជាតិ ខ្មែរ , ឈ្មោះ [redacted] ប្រុស អាយុ ៥៦ ឆ្នាំ ជាតិ ខ្មែរ , ឈ្មោះ [redacted] ភេទ ប្រុស អាយុ ៣០ ឆ្នាំ ជាតិ ខ្មែរ និងឈ្មោះ [redacted] ភេទ ប្រុស អាយុ ២៧ ឆ្នាំ ជាតិ ខ្មែរ បានរួមគំនិតគ្នាប្រើប្រាស់ ឧបករណ៍នូវ ទួឈើវែស និងពូថៅ ធ្វើជាអាវុធវាយជនរងគ្រោះឈ្មោះ [redacted] និងឈ្មោះ [redacted] បណ្តាលឲ្យទទួលរងរបួស លើរូបរាងកាយយ៉ាងប្រាកដមែន ។

-តាមចំលើយជនជាប់ចោទឈ្មោះ [redacted] និងឈ្មោះ [redacted] បានឆ្លើយនៅគ្រប់ដំណាក់កាលនីតិវិធី ជាពិសេសនាពេលសវនាការ ប្រហាក់ប្រហែលគ្នាថានៅថ្ងៃកើតហេតុខ្លួនបានទទួលស្គាល់ ថាពិតជាបានរួមដំណើរគ្នា នៅពេលវេលាដូចការចោទប្រកាន់ខាងលើទៅកាន់ទីកន្លែងចំនុចកើតហេតុ គឺមានភាពស៊ីចង្វាក់គ្នាយ៉ាងខ្លាំងទៅនិងចំលើយសាក្សីឈោះបន្ទុកឈ្មោះ [redacted] បានឆ្លើយថាអ្នកទាំងពីរនាក់ប្តីប្រពន្ធនេះ

ពេលកើតហេតុពួកគាត់ពិត ជាបានដើរសំដៅទៅចំនុចកើតហេតុពិតប្រាកដមែន ។ ចំលើយទទួលស្គាល់យ៉ាងនេះបានផ្តល់ផលប្រយោជន៍យ៉ាងដាក់បន្ទុកខ្លាំងលើខ្លួនដោយមាន ស៊ីចង្វាក់គ្នាជាមួយចំលើយឲ្យការរបស់ជនរងគ្រោះទាំងពីរនាក់ និងសាក្សីដាក់បន្ទុកទាំងអស់ដូចរៀប រាប់តាមចំនុចខាងលើថាឈ្មោ[redacted] ណៈពេលកំពុង កើតហេតុវាយតបគ្នាពួកគេពិតជា មានវត្តមានបានធ្វើសកម្មភាពរួមជាមួយបងប្អូនខ្លួនឈ្មោះ [redacted] ដែលកំពុងរត់គេចខ្លួនក្នុងអំពើវាយប្រហារ លើជនរងគ្រោះទាំងពីរនាក់យ៉ាងពិតប្រាកដ។ រីឯចម្លើយបដិសេធរបស់ពួកខ្លួនថា ពុំបានចូលរួមប្រព្រឹត្តដូចការចោទគ្មានភស្តុតាងបញ្ជាក់អាចឱ្យតុលាការទទួលយកជាភស្តុតាងដោះបន្ទុកបានទេ ។

-បានឃើញរបាយការណ៍សំយោគលេខៈ ១១៣ របក ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១២ របស់អធិការដ្ឋាន នគរបាល ខណ្ឌដូនពេញ នៃស្នងការដ្ឋាន នគរបាលរាជធានីភ្នំពេញ បានបញ្ជាក់យ៉ាងច្បាស់លាស់ពីអំពើនិងសកម្មភាពប្រព្រឹត្តល្មើស របស់ជនជាប់ចោទឈ្មោ[redacted] ស្រី អាយុ ២៩ ឆ្នាំ ឈ្មោ[redacted]ភេទ ប្រុស អាយុ ៥៦ ឆ្នាំ ឈ្មោ[redacted]ភេទ ប្រុស អាយុ ៣០ ឆ្នាំ និងឈ្មោះ[redacted] ភេទ ប្រុស អាយុ ២៧ ឆ្នាំ ពីបទៈ ហឹង្សាដោយចេតនា មានស្ថានទម្ងន់ទោស ស្ថិតនៅទីកន្លែងនិងពេលវេលាដូចខាងលើតាមបទបញ្ញត្តិមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ប្រាកដមែន ។

-បានឃើញកំណត់ហេតុ ឯកសារ ភស្តុតាង នានាធ្វើឡើងដោយ មន្ត្រីនគរបាលយុត្តិធម៌ អយ្យការ ចៅក្រមស៊ើបសួតជាភស្តុតាង ។

-តាមសេចក្តីសន្និដ្ឋានរបស់លោក [redacted]និងលោ[redacted]ជាមេធាវី ការពារក្តីឲ្យដើមបណ្តឹងជាជនរងគ្រោះឈ្មោះ[redacted]និងឈ្មោះ[redacted]សន្និដ្ឋាន បញ្ជាក់ថាៈ នៅក្នុងអង្គហេតុនេះគឺកើតឡើងដោយសារ កន្លងមកឈ្មោះ [redacted] គាត់បានបាត់កញ្ចក់រថយន្ត ហើយគាត់សង្ស័យលើជនរងគ្រោះទាំងពីរនាក់ ទើបគាត់បាននាំប្អូនគាត់ទាំងពីនាក់មកបំណងសំលាប់ ជនរងគ្រោះប៉ុន្តែសំណាងល្អដោយ មានការជួយអន្តរាគមន៍ទាន់ពេលវេលាពីសំណាក់អ្នកផ្សេង ក៏ដូចជាឪពុកជនរងគ្រោះទើបនៅពេលកើតហេតុ ជនរងគ្រោះទាំងពីរនាក់បានរួចផុតពីសេចក្តីស្លាប់បាត់បង់ជីវិត ។ តាមអង្គហេតុបង្ហាញឲ្យ ឃើញថាជនរងគ្រោះទាំងពីរនាក់ពិតជាត្រូវ ទទួលរងនូវព្យសនកម្មលើរូបរាងកាយនិងផ្លូវចិត្តជាពិសេសចំនុចជង់ខ្លួន-ក្បាលជនរងគ្រោះដូចក្នុងសំបុត្រពេទ្យបញ្ជាក់ស្នាមរបួសស្នាមជាច្រើនកន្លែងដោយជនដៃដល់ពីរនាក់គឺឈ្មោះ [redacted]និងឈ្មោះ [redacted]បានប្រើប្រាស់នូវឧបករណ៍ដូចជា ពូថៅ និងទួលីដែក ធ្វើជាអាវុធដើម្បីកាប់ចាក់ សំលាប់លើជនរងគ្រោះ ដោយមានឈ្មោះ[redacted] ជាអ្នក បង្កុលបង្ហាញ និងបញ្ជាព្រមទាំងជួយអន្តរាគមន៍ផ្ទាល់ក្នុងអំពើនេះឲ្យបងប្អូនរត់គេចខ្លួន ។ ហេតុនេះក្នុងនាមជាមេធាវីការពារជនរងគ្រោះខ្លួនសំនូមពរតុលាការកែប្រែបទចោទប្រកាន់ មកបទល្មើសប៉ុនប៉ងមនុស្សឃាតដោយចេតនាវិញ ។ ជាសេចក្តីសន្និដ្ឋានមានលក្ខណៈ ត្រឹមត្រូវតាមអង្គហេតុជាក់ស្តែងនៃបទល្មើសខាងលើគប្បីតុលាការពិចារណា /



Scanned by CamScanner

ផងដែរប៉ុន្តែ តុលាការមិនអាចទទួលយកពិចារណា និងសំរេចប្តូរបទចោទប្រកាន់ទៅបទ ប៉ុនប៉ងមនុស្ស ឃាតបានទេព្រោះ អំពើនិងសកម្មភាពរបស់ជនជាប់ចោទប្រព្រឹត្តដូចខាងលើពុំទាន់មាន ធាតុផ្សំគ្រប់គ្រាន់ បទល្មើសដូចការស្នើរសុំលោកមេធាវីលើកឡើងទេ តែមានធាតុផ្សំគ្រប់ គ្រាន់ពីបទ ហឹង្សាដោយចេតនា មានស្ថានទម្ងន់ទោស ដូចការចោទប្រកាន់ខាងលើហេតុនេះតុលាការរក្សាទុកជា បានការដដែល។

–សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការនាពេលសវនាការថា: ឆ្លងតាមការសួរដេញដោលចំលើយសាក្សីនានា , ភស្តុតាងរូបថត និងសំបុត្រពេទ្យបញ្ជាក់របួសស្នាមជនរងគ្រោះ សន្និដ្ឋានបានថាពិតជាមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើបទល្មើសបទ ហឹង្សាដោយ ចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តស្ថិតនៅទីកន្លែងនិងពេលវេលាដូចខាងលើដែលបង្ករឡើងដោយជនជាប់ចោទទាំងបួននាក់ខាងលើពិតប្រាកដមែន ហេតុនេះតំណាងអយ្យការសូមតំកល់ បទចោទប្រកាន់ដូចក្នុងសេចក្តីសន្និដ្ឋានស្ថាពរទុកជាបានការដដែលដោយប្តឹងសុំតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។ ជាសេចក្តីសន្និដ្ឋានមាន លក្ខណៈត្រឹមត្រូវតាមច្បាប់ ជាហេតុតុលាការគប្បីពិចារណានិងសំរេច ។

–<u>សេចក្តីសន្និដ្ឋានរបស់លោក</u>[redacted] <u>មេធាវីការពារក្តីឲ្យជនជាប់ចោទឈ្មោះ</u>[redacted]<u>បានធ្វើសេចក្តីសន្និដ្ឋានរួមគ្នានាពេលសវនាការថា:</u> នៅពេលវេលា និងទីកន្លែងដូចការចោទប្រកាន់ខាងលើ ពិតជាកើត មានអង្គហេតុវាយតប់គ្នានៅមុខផ្ទះសំណាក់បុប្ផា មែនដែលក្នុងអង្គហេតុនេះជនរងគ្រោះ ឈ្មោះ[redacted]និងឈ្មោះ[redacted]បានទៅប្តឹងប៉ូលីសចោទប្រកាន់លើកូនក្តីខ្លួនថា អ្នករួមគំនិតគ្នាប្រព្រឹត្តលើខ្លួន ។ អង្គហេតុហឹង្សានេះពុំមានឈ្មោះ[redacted] ចូលរួមប្រព្រឹត្តដើម្បីវាយលើជនរងគ្រោះទាំងពីរនាក់ខាងលើនោះទេ ។ ដោយមូលហេតុសំអាងចំនុចមួយចំនួនដូចខាងក្រោម៖

•ភស្តុតាងដូចជា ពូថៅ និង ទូលីវីស មន្ត្រីនគរបាលយុត្តិធម៌ពុំបានប្រមែប្រមូល បានមកដាក់ក្នុងសំណុំរឿងដើម្បីបង្ហាញភស្តុតាងទេ ។

•ចំលើយបំភ្លឺរបស់សាក្សី និងជនរងគ្រោះមិនមានភាពស៊ីចង្វាក់គ្នាទេ ។

•នៅថ្ងៃកើតហេតុនៅពេលវេលានិងទីកន្លែងដូចខាងលើកូនក្តីខ្លួនពុំមានវត្តមានទេដូចសាក្សីដោះបន្ទុកឈ្មោះ[redacted]បានបញ្ជាក់ថាកូនក្តីខ្លួនពេលកើតហេតុហឹង្សា ពួកគេកំពុងឈរជជែកគ្នាពីរឿងដីធ្លី ពុំមានទាក់ទងអង្គហេតុហឹង្សាដោយចេនានោះទេ ។

•តាមចំលើយឪពុករបស់ជនរងគ្រោះឈ្មោះ[redacted] ថាកូនក្តីខ្លួនចាប់ទាញដៃប្រឡេះដើម្បីឲ្យប្អូនរត់គេច ក្រៅពីនេះពុំមានសាក្សីណាបញ្ជាក់ឲ្យច្បាស់ទេនៅក្នុងកំណាត់ហេតុកន្លងមក ។

•វត្តមានកូនក្តីខ្លួនស្ថិតនៅកន្លែងកើតហេតុ គឺស្ថិតក្នុងស្ថានភាពចៃដន្យបំផុត ព្រោះគាត់ម្នាក់ទៅរកទិញអីហូប រីឯម្នាក់ទៀតគាត់ទៅហាត់ប្រាណពុំទាក់ទងទៅនឹងអំពើហឹង្សាទេ ។

•វត្តមានកូនក្តីខ្លួននៅកន្លែងកើតហេតុពុំមែនជាភស្តុតាងដាក់បន្ទុកទេ ។

•ការចោទប្រកាន់កូនក្តីខ្លួនដូច្នេះ ខុសហើយផ្អែកតាមមាត្រា ២៤១ នៃក្រមព្រហ្មទណ្ឌ ចែងថា គឺអ្នកណាប្រព្រឹត្តអ្នកនោះទទួលខុសត្រូវ ពុំអាចចាប់កូនក្តីខ្លួនទទួលខុសត្រូវជំនួស នោះទេ និងផ្អែកតាមមាត្រា ៤ នៃក្រមព្រហ្មទណ្ឌកូនក្តីខ្លួនគ្មានចេតនាប្រព្រឹត្តទេ ។

•ផ្អែកតាមចំលើយសាក្សីឈ្មោះ[redacted] ចំលើយវិមតិសង្ស័យ ព្រោះថាហេតុអ្វីស្គាល់ជនជាប់ចោទច្បាស់ម្ល៉េះ នៅក្នុងកំណត់ ហេតុ តាំងពីត្រកូល អាយុ ការស្គាល់ជនជាប់ចោទមានតែសមត្ថកិច្ចមូលដ្ឋានទេ ។ ចំពោះ ទូលីវីស ដែលសាក្សីថាឃើញមាន ដងខៀវ តើម៉ោងពេលយប់ងងឹតទៀត យ៉ាងម៉េចមើល ឃើញទៅ នេះជាបុរេវិនិច្ឆ័យរបស់សាក្សីតែប៉ុណ្ណោះ ។ ការលើកឡើងរបស់សាក្សីឈ្មោះ [redacted]ឆ្លើយតាមនឹកឃើញតែប៉ុណ្ណោះ សាក្សីនេះគ្មានវត្តមាននៅកន្លែងកើតហេតុទេ រីឯសាក្សីឈ្មោះ [redacted]ាត់មានទំនាស់ផលប្រយោជន៍ព្រោះជនរងគ្រោះទាំងពីរ នាក់ គាត់ត្រូវជាកូននិងក្មួយជាអ្នកប្តឹងហើយឪពុកធ្វើជាសាក្សី ។ ការឃើញរបស់គាត់មាន ភាព ស្រពិចស្រពិលណាស់គាត់ថាឈ្មោះ [redacted]ន្លង គាត់ជាអ្នកចាប់ចំលើយនៅសមត្ថ កិច្ច នៅតុលាការគាត់ជាអ្នកចាប់ជាមួយអ្នករត់ម៉ូតូឌុប ជាចំលើយខុសគ្នាមិនអាចដាក់បន្ទុក លើ កូនក្តីខ្លួនបានទេ ។

•ចំពោះចំលើយរបស់ដើមបណ្តឹងជាជនរងគ្រោះទាំងពីរនាក់ ជាមនុស្សស្ថិតនៅក្នុង ស្ថានភាពស្រវឹងខ្លាំង ជាពតិមានមនុស្សស្រវឹងបាត់បង់ស្មារតីសុំបដិសេធចំលើយជនទាំង ពីរនាក់នេះ ។

ផ្អែកតាមលើកឡើងដូចខាងលើនេះ គឺជាវិមាតិសង្ស័យត្រូវបានជា ប្រយោជន៍ដល់ ជនជាប់ចោទ ហេតុនេះស្នើសុំតុលាការសំរេចឲ្យ កូនក្តីខ្លួនទាំងពីរនាក់ខាងលើឲ្យរួចខ្លួនពី បទចោទប្រកាន់ និងសុំបដិសេធចោទចំពោះការប្តឹងទាមទារសំណងរបស់ភាគីដើមបណ្តឹង បដិសេធការលើកឡើង របស់មេធាវីការពារជនរងគ្រោះបាន ស្នើសុំតុលាការកែប្រែបទ ចោទ ប្រកាន់ទៅបទប៉ុនប៉ងមនុស្សឃាតវិញគឺមិនអាចទៅរួចទេ ។

តាមសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីឲ្យជនជាប់ចោទឈ្មោះ[redacted] និង ឈ្មោះ [redacted]ានលើកឡើងដូចចំនុចខាងលើ តុលាការបានកត់សំគាល់ឃើញថា៖ មេធាវីការពារក្តីជនជាប់ចោទឈ្មោ[redacted]ងឈ្មោះ[redacted]បានទទួលស្គាល់ ថា ពិតជាកើតមានអង្គហេតុ ហឹង្សាដោយចេតនា មានស្ថានទម្ងន់ទោស ស្ថិតនៅទីកន្លែង និងពេលវេលាដូចការចោទប្រកាន់ខាងលើមែន ប៉ុន្តែនៅក្នុងព្រឹត្តហេតុនេះ កូនក្តីខ្លួនពុំបាន ចូលរួមប្រព្រឹត្តទេ គឺមនុស្សផ្សេងជាអ្នកប្រព្រឹត្តល្មើស ទៅលើជនរងគ្រោះ ទាំងពីរនាក់ ឈ្មោះ [redacted]នោះ ។ កូនក្តីខ្លួនទាំងពីរនាក់ប្តីប្រពន្ធ បានទៅ កន្លែងកើតហេតុ ដោយភាពចៃដន្យតែប៉ុណ្ណោះ ជាសេចក្តីសន្និដ្ឋានគ្មានមូលដ្ឋាន ភស្តុតាង ដោះបន្ទុកគ្រប់គ្រាន់អាចឲ្យតុលាការជឿជាក់ ទទួលយកពិចារណានិងសំរេច បានឡើយ ។

ដោយមូលហេតុថា៖

+អង្គហេតុខាងលើនេះ ពិតជាកើតឡើងដោយមានមូលហេតុពិតប្រាកដគឺដោយសារ ដំបូងឡើងគឺឈ្មោះ [redacted]និងប្តីមានចោរលួចបាត់កញ្ចក់រថយន្តរបស់ខ្លួនហើយប្តឹង ទៅសមត្ថកិច្ចស្រាវជ្រាវរកមិនឃើញ ទើបសង្ស័យលើជនរងគ្រោះទាំងពីរនាក់នេះថាអ្នក



Scanned by CamScanner

ប្រព្រឹត្តលួចកញ្ចក់រថយន្តខ្លួនទើបបាននាំបងប្អូនឈ្មោះ [redacted] ទៅវាយ ជនរងគ្រោះយ៉ាងដូច្នោះ។

+ផ្អែកតាមចំលើយទទួលស្គាល់របស់ឈ្មោះ [redacted] នៅគ្រប់ដំណាក់កាលនីតិវិធីសាកសួរចំលើយ បានបញ្ជាក់ថាខ្លួនពិតជាបានទៅ កន្លែងកើតហេតុពិតប្រាកដមែន គឺស៊ីសង្វាក់គ្នាទៅនិងចំលើយសាក្សីដោះបន្ទុកឈ្មោ [redacted] ក៏បានឆ្លើយបញ្ជាក់គ្រប់ដំណាក់កាលនីតិវិធី ថាពេលកើតហេតុអ្នកទាំងពីរនាក់ប្តីប្រពន្ធនេះពិតជាបានរួមដំណើរនៅកន្លែងកើតហេតុមែន ត្រង់ចំនុចនេះបានបញ្ជាក់ ឲ្យឃើញថាមានភាពស៊ីសង្វាក់គ្នាយ៉ាងខ្លាំងទៅនឹងចំលើយសាក្សីដាក់បន្ទុកទាំងអស់ និងចំលើយជនរងគ្រោះបានបញ្ជាក់ដូចៗគ្នាថា ពួកគាត់ទាំងពីរនាក់ប្តីប្រពន្ធ ពិតជាមានវត្តមាននៅកន្លែងកើតហេតុហើយថែមទាំងបានចូលរួមធ្វើសកម្មភាពដោយផ្ទាល ដោយបញ្ជានិងរំដោះបងប្អូនជាអ្នកប្រព្រឹត្តឲ្យ រត់គេចខ្លួនពីកន្លែងកើតហេតុទៀតផង ។

+តាមចំលើយសាក្សីដោះបន្ទុកឈ្មោ [redacted] គាត់បានបញ្ជាក់ថាអ្នកទាំងពីរនាក់ប្តីប្រពន្ធខាងលើ ពិតជាបានធ្វើដំណើរទៅកន្លែងកើតហេតុមែន ហើយខ្លួនពុំបានធ្វើដំណើរទៅកន្លែងកើតហេតុទេ គឺគាត់នៅផ្ទះរបស់គាត់ប៉ុន្តែគាត់សន្និដ្ឋានថាអ្នកទាំងពីរនាក់ប្តីប្រពន្ធ ពុំបានចូលរួមប្រព្រឹត្តហឹង្សាជាមួយបងប្អូនគាត់ចំពោះជនរងគ្រោះទេការបញ្ជាក់សាក្សី ត្រង់ចំនុចនេះតុលាការមិនជឿជាក់ ទទួលយកជាភស្តុតាងដោះបន្ទុកបានទេព្រោះហេតុអ្វីគាត់ដឹងបើគាត់មិនបានទៅមានវត្តមានកន្លែងកើតហេតុផងនោះហើយមានភស្តុតាងណាមកបញ្ជាក់បន្ថែមលើការអះអាងសាក្សីនេះទេបើ គាត់ពុំតាមឃ្លាំមើលជាប់គ្នារហូតនូវសកម្ម ភាពទាំងពីរនាក់ប្តីប្រពន្ធនេះផង ហើយគាត់ស្ថិតនៅឆ្ងាយពីគ្នាយ៉ាងដូចច្នេះទៀតផងពីកន្លែងកើតហេតុ ។

+បើទោះបីកំលាំងសមត្ថកិច្ច ពុំប្រមូលបានភស្តុតាងនូវ ទូលីវែស និង ពូថៅ ពីជនជាប់ចោទពិតមែនដោយសារជនជាប់ចោទដែលរត់គេចខ្លួនគឺឈ្មោះ [redacted] គបានរឹបយកទៅតាមខ្លួនបាត់ទៅហើយ ប៉ុន្តែមានចំលើយសាក្សី និងជនរងគ្រោះដែល ស្ថិតនៅកន្លែងកើតហេតុបានបញ្ជាក់យ៉ាងច្បាស់ ហើយថានៅកន្លែងកើតហេតុវាយតប់គ្នា នេះគឺបានឃើញជនល្មើសឈ្មោ [redacted] បានប្រើប្រាស់ ពូថៅ និង ទូលីវែស ធ្វើជាមធ្យោបាយកាប់ចាក់មកលើពួកខ្លួនយ៉ាងពិតប្រាកដ ។ ម្យ៉ាងទៀត នៅពេលប្រតាយប្រតប់គ្នានោះ ជនល្មើសបានជ្រុះទូលីវែសពីដៃធ្លាក់ទៅដីដែលទីកន្លែង នោះមានភ្លើងអគ្គីសនី ភ្លឺមើលឃើញច្បាស់តែជនល្មើសបាន រើសយកវិញដើម្បីរត់គេចខ្លួន ស៊ីចង្វាក់គ្នាទៅ នឹងស្លាកស្នាមរបួសនៅជនរងគ្រោះ គឺមានលិខិតបញ្ជាក់របស់ពេទ្យនិងរូប ថតធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌ជាភស្តុតាងស្រាប់ ។

+ផ្អែកតាមចំលើយដើមបណ្តឹងជាជនរងគ្រោះ ទាំងពីរនាក់ក៏ដូចចំលើយសាក្សីឈ្មោះ [redacted] នឆ្លើយប្រហាក់ប្រហែលគ្នាថា: មុនកើតហេតុពួកគេឃើញមនុស្សប្រុសម្នាក់ស្ត្រីម្នាក់ដើរមកមុនហើយចង្អុលសំដៅទៅជនរងគ្រោះ ប្រាម់ទៅមនុស្សប្រុសពីរនាក់ទៀតដែលម្នាក់កាន់ពូថៅ និងម្នាក់ដៃកាន់ទូលីវែស បញ្ជាក់ថាហ្នឹងហើយចោរ ពេលនោះអ្នកទាំងពីរបានសំរុកចូល វាយ កាប់ ចាក់ ទៅលើជនរងគ្រោះទាំងពីរនាក់ក្នុងពេលនោះតែម្តង ។



Scanned by CamScanner

ត្រង់ចំនុចនេះបានបញ្ជាក់ឲ្យឃើញថា ជនជាប់ចោទទាំងអស់គឺ មានគំនិតចេតនាទុចរិត រៀបចំផែនការទុកជាមុនរួចស្រេចទៅហើយ ពុំមែនដូចការលើកឡើងរបស់លោក មេធាវីការពារក្តីជនជាប់ចោទថាកូនក្តីខ្លួនគ្មានធាតុចេតនាប្រព្រឹត្តល្មើសដូចចែងក្នុងមាត្រា ៤ នៃក្រម ព្រហ្មទណ្ឌទេ ។

+ការលើកឡើងថាចំលើយបំភ្លឺរបស់សាក្សីឈ្មោះ [redacted] ជាចំលើយវិមតិសង្ស័យ ព្រោះហេតុអ្វីស្គាល់ត្រកូល អាយុ និងឃើញ ទូលីវីស របស់ជនជាប់ចោទច្បាស់ម្ល៉េះ មិនអាចទទួលយកបានទេហើយចំលើយមានការ ប្រែប្រួលធ្វើខុសៗគ្នា គឺសាក្សីទាំងនោះពុំមានវត្តមានកន្លែងកើតហេតុទេ ការលើកឡើង ចំនុចទាំងនេះគឺ ពុំមានមូលដ្ឋានភស្តុតាងដោះបន្ទុកគ្រប់គ្រាន់បញ្ជាក់ពី វិមតិសង្ស័យលើ ជនជាប់ចោទទាំងអស់នោះទេព្រោះថា លោកមេធាវីការពារក្តីជនជាប់ចោទគាត់បានលើកឡើងតែចំនុចចម្លើយប្រែប្រួលដោយមានការភ្លេចភ្លាំងខុសគ្នាបន្តិចបន្តួចប៉ុណ្ណោះ របស់ជនរងគ្រោះ និងសាក្សីដាក់បន្ទុកគ្រាន់តែជាចំនុចមួយតូចប៉ុណ្ណោះនៃភស្តុតាងដាក់បន្ទុកទាំងមូលមកធ្វើជាភស្តុតាងដោះបន្ទុក ឲ្យកូនក្តីខ្លួនរួចខ្លួនក្នុងបទចោទប្រកាន់ ដែលពុំមានមូលដ្ឋានភស្តុតាងណាផ្សេងមកបញ្ជាក់ អាចឲ្យតុលាការពិចារណាទទួលយក និងសំរេចបានទេ រីឯការលើកឡើងថាសាក្សីឈ្មោះ [redacted] ថាទំនាស់ផលប្រយោជន៍ជាមួយជនរងគ្រោះនោះ ត្រង់នេះគ្មានបទបញ្ញត្តិនៃ ច្បាប់ណាមកហាមឃាត់ មិនឲ្យសាច់ញាតិផ្ទាល់ជាមួយជនរងគ្រោះ ឬជនជាប់ចោទមិន អាចក្លាយជាសាក្សីក្នុងរឿងក្តីបានទេ ពិសេសសាក្សីបានបំពេញកិច្ចសច្ចមុនឆ្លើយតាមបទបញ្ញត្តិច្បាប់ហើយ ។ ម្យ៉ាងទៀតស្ថានភាពជនរងគ្រោះទាំងពីរនាក់ពុំស្ថិត ក្នុងភាពស្រវឹងស្រាបាត់បង់ស្មារតីនោះទេ ពួកគេនៅមានសតិយល់ដឹងច្បាស់លាស់បានរត់គេចខ្លួន ពីអំពើវាយប្រហាពីសំណាក់ជនជាប់ចោទ ហើយពួកគេបានមើលឃើញទង្វើរប្រព្រឹត្តរបស់ជនជាប់ចោទ នឹងស្គាល់ច្បាស់ជនជាប់ចោទទាំងអស់ទៀតផង ។

<u>សរុបសេចក្តីមក:</u> សេចក្តីសន្និដ្ឋានរបស់លោកមេធាវីការពារក្តីឲ្យជនជាប់ចោទឈ្មោះ [redacted] នបញ្ជាក់ថាកូនក្តីខ្លួនមានភស្តុតាងបញ្ជាក់ពី វិមតិសង្ស័យនោះដោយសុំឲ្យតុលាការសំរេច ឲ្យរួចខ្លួនពីបទចោទប្រកាន់ខាងលើនោះមិនអាចឲ្យតុលាការទទួលយកបានឡើយ ព្រោះផ្អែកតាមភស្តុតាងដាក់បន្ទុក ច្រើនលើសលុបដូចបានរៀបរាប់ខាងលើជា: ចំលើយបញ្ជាក់របស់ជនរងគ្រោះ,សាក្សីដាក់បន្ទុកនានា,វត្តមានរបស់ឈ្មោះ [redacted] កន្លែងកើតហេតុដោយផ្ទាល់ជាមួយបងប្អូនខ្លួនឈ្មោះ [redacted] ជាជនដៃដល់ធ្វើសកម្មភាពយ៉ាងសកម្មវាយជនរង គ្រោះដែលភស្តុតាងសំខាន់បំផុតនោះ គឺពុំមែនជនជាប់ចោទទាំងពីរនាក់ប្តីប្រពន្ធនេះទៅមានវត្តមានកន្លែងកើតហេតុដោយភាពចៃដន្យទេ ព្រោះជនជាប់ចោទទាំង អស់សុទ្ធសឹងតែជាសាច់សាលោហិតជាមួយគ្នាហើយរវាងជនរងគ្រោះនិងជនជាប់ចោទគឺស្គាល់គ្នាយ៉ាងច្បាស់លាស់ទៀតផង ហេតុនេះមានការរៀបចំផែនការទុកជាមុនយ៉ាងច្បាស់លាស់ ។ ស្ថានភាពទាំងអស់ដូចរៀបរាប់ខាងលើនេះបាន បញ្ជាក់ឲ្យឃើញថា ពុំមានវិមតិសង្ស័យលើជនជាប់ចោទចោទទាំងពីរនាក់ខាងលើឡើយ។



Scanned by CamScanner

-ដើមបណ្តឹងរដ្ឋប្បវេណីជាជនរងគ្រោះឈ្មោ[redacted]ឈ្មោះ [redacted]ពួក គេបានប្តឹងទាមទារសំណងថ្លៃសេវាព្យាបាលជម្ងឺ និងសុខភាពរួមទាំងជម្ងឺចិត្តក្នុងម្នាក់ៗ ចំនួន ១០.០០០.០០ ដុល្លាអាមេរិក ( មួយម៉ឺនដុល្លាអាមេរិក ) ពីជនជាប់ចោទទាំងបួននាក់ ខាងលើ គឺធ្វើឡើងមាន លក្ខណៈសមស្រមតាមច្បាប់តែតុលាការគប្បីពិចារណា និងសំរេច ឲ្យបានសមស្របទៅនិង ជីវភាពជាក់ស្តែងរបស់ជនជាប់ចោទ និងជីវភាពសង្គមកម្ពុជាសព្វ ថ្ងៃ ។

-ស្ថានភាពអំពីការផ្តន្ទាទោស: ជនជាប់ចោទឈ្មោ[redacted]ពួកគេទាំងបីនាក់ជាអ្នកលូកដៃប្រព្រឹត្តល្មើសយ៉ាង សកម្ម វាយប្រហារទៅលើ ជនរងគ្រោះទាំងពីរនាក់ខាងលើ ដោយផ្ទាល់បន្ទាប់ពីប្រព្រឹត្ត ល្មើសរួច ពួកគេបានរត់គេចខ្លួនបាត់ ស្ថានភាពទាំងនេះនាំឲ្យតុលាការពិចារណា និងសំរេច ផ្តន្ទាទោសពន្ធនាគារកំរិតប្រហាក់ប្រហែលកំរិតអតិប្បរមាទោសនៃច្បាប់បានបញ្ញត្តិ។
រីឯឈ្មោះ [redacted]ជាបក្សពួករួមគំនិតគ្នាក្នុងការ ប្រព្រឹត្ត បទល្មើសខាងលើនេះមែន ប៉ុន្តែគេពុំមែនជាជនសកម្មក្នុងការប្រព្រឹត្តល្មើសជាមួយ បក្សពួកខ្លួន គប្បីតុលាការពិចារណាអនុគ្រោះទោសដោយសំរេចអនុញ្ញាតឲ្យទទួលបានទោស ពន្ធនា គារព្យួរទាំងអស់តាមមាត្រា ១០៦,១០៧,១០៨ នៃក្រមព្រហ្មទណ្ឌ ។

-ជនជាប់ចោទឈ្មោះ [redacted]ទូអ្នកទាំងពីរនាក់ ពេលប្រព្រឹត្តល្មើសរួចកំពុងរត់គេចខ្លួនតុលាការគប្បីសំរេចផ្តន្ទាទោសដោយបង្គាប់ឱ្យចាប់ ខ្លួនមកទទួលទោសពន្ធនាគារតាមអំណាចសាលក្រមតាមមាត្រា ៣៥៣ នៃក្រមនីតិវិធី ព្រហ្មទណ្ឌ ។

-សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] តុលាការបានពិចារណាផងដែរ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១/ផ្តន្ទាទោសលើ ជនជាប់ចោទដូចខាង ក្រោម៖

-ឈ្មោះ [redacted]ភេទ ស្រី អាយុ ២៩ ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធ នាគារ កំណត់ ០៣ ឆ្នាំ (បីឆ្នាំ) ( កំពុងជាប់ឃុំ )។

-ឈ្មោ[redacted]ភេទ ប្រុស អាយុ ៣០ ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធ នាគារ កំណត់ ០៣ ឆ្នាំ (បីឆ្នាំ) (កំពុងរត់ គេចខ្លួន) ។

-ឈ្មោះ [redacted]ទ ប្រុស អាយុ ២៧ ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០៣ ឆ្នាំ (បីឆ្នាំ) (កំពុងរត់គេចខ្លួន) ។

-ឈ្មោះ [redacted]ទ ប្រុស អាយុ ៥៦ ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០៣ ឆ្នាំ (បីឆ្នាំ) តែអោយទទួលទោសគុក ព្យួរទាំងអស់ ។



Scanned by CamScanner

ពីបទ: ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំនុចមុខផ្ទះ សំណាក់បុប្ផា ទីតាំងផ្ទះលេខ ៥ ផ្លូវលេខ ៨៦ ភូមិ ២២ សង្កាត់ស្រះចក ខណ្ឌ ដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១២ ។

បទល្មើសព្រហ្មទណ្ឌ ដែលមានចែងនិង ផ្តន្ទាទោសតាមបញ្ញត្តិមាត្រា១០៦,១០៧ ១០៨ និងមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ។

២/បង្គាប់ឱ្យជនជាប់ចោទឈ្មោះ [redacted]ទស្រី អាយុ ២៩ ឆ្នាំ ជាតិខ្មែរ,ឈ្មោ[redacted]ទ ប្រុស អាយុ ៥៦ ឆ្នាំ ជាតិខ្មែរ,ឈ្មោះ [redacted] ភេទ ប្រុស អាយុ ៣០ ឆ្នាំ ជាតិខ្មែរ និងឈ្មោ[redacted]ប្រុស អាយុ ២៧ ឆ្នាំ ជាតិខ្មែរ រួមគ្នាសងសំណងអន្តរាយផ្សេងៗ និងជម្ងឺ ចិត្តដល់ដើមបណ្តឹង និងជាជនរងគ្រោះ ចំនួនសរុបដូចខាងក្រោម:

-ឈ្មោះ [redacted] ប្រុស អាយុ ២៦ ឆ្នាំ ជាតិខ្មែរ ចំនួន ៣០.០០០.០០០ រៀល ( សាមសិបលាន រៀល ) ។

-ឈ្មោះ [redacted]ទ ប្រុស អាយុ ២៤ ឆ្នាំ ជាតិខ្មែរ ចំនួន ៣០.០០០.០០០ រៀល ( សាមសិបលាន រៀល ) ។

ដើមបណ្តឹងរដ្ឋប្បវេណី ទាមទារលើសពី នេះបដិសេធចោល ។

តាមមាត្រា ៣៥៥ នៃក្រមនីតិវិធី ព្រហ្មទណ្ឌ ។

៣/បង្គាប់ឱ្យចាប់ខ្លួនឃុំខ្លួនឈ្មោះ [redacted]ភេទ ប្រុស អាយុ ៣០ ឆ្នាំ និងឈ្មោះ[redacted] ប្រុស អាយុ ២៧ ឆ្នាំ (មានអត្តសញ្ញាណដូចខាងលើ) នៅពន្ធនាគារម១ព្រៃស នៃក្រសួងមហាផ្ទៃ។

តាមមាត្រា ៣៥៣ នៃក្រមនីតិវិធី ព្រហ្មទណ្ឌ ។

៤/សាលក្រមនេះជំនុំជំរះជាសាធារណៈ នាថ្ងៃទី ២៦ , ២៧ ខែ ធ្នូ ឆ្នាំ ២០១២ ចំពោះមុខជនជាប់ចោទឈ្មោះ[redacted] [redacted]មេធាវីជនជាប់ចោទទាំងពីរនាក់ , ដើមបណ្តឹងនិងជាជនរងគ្រោះឈ្មោះ[redacted],មេធាវីការពារដើមបណ្តឹង និងកំបាំងមុខ ជនជាប់ចោទឈ្មោះ [redacted] ឈ្មោះ[redacted]ដោយប្រកាសជាសាធារណៈនាថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១២

ទុកសិទ្ធិប្តឹងទាស់ និងបើកផ្លូវប្តឹងឧទ្ធរណ៍ តាមកំណត់ច្បាប់ ។

| | |
|---|---|
| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមជំនុំជម្រះ** |
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |
| [redacted] | [redacted] |

| | |
|---|---|
| បានឃើញ | បានចម្លងត្រឹមត្រូវតាមច្បាប់ដើម |
| **ចៅក្រមជំនុំជម្រះ** | រាជធានីភ្នំពេញថ្ងៃទី៣១ខែ ធ្នូ ឆ្នាំ២០១២ |
| [redacted] | **ក្រឡាបញ្ជី** |
| | [redacted] |



Scanned by CamScanner